មេរៀនបន្ថែមស្តីអំពី
ការកសាងចរិកលក្ខណៈ

# ថ្នាក់មធ្យម កំរិត ២

រៀបរៀងដោយលោកគ្រូគង្វាល ជេ. ជេ. លិម
ដោយមានការពិគ្រោះយោបល់ពីលោកគ្រូគង្វាល ដេវីឌ ហីកស៍

បោះពុម្ពនៅខែធ្នូ ឆ្នាំ២០១០

Copyright © Gratia Dei Sola Media

**Character Building Supplement**

By Ps J.J.Lim;
with helpful contributions by Ps David Higgs

©2013 by Pilgrim Covenant Church

Khmer Language version © Gratia Dei Sola Media

Published by Gratia Dei Sola Media

Blk 203B, Henderson Road,#07-07,Singapore 159546.
Website: www.gdsmedia.org
Email:gdsmedia.sg@gmail.com

All rights reserved  Printed in Singapore

Copyright © Gratia Dei Sola Media

# មាតិកា


អារម្ភកថា ........................................................ ៤
មេរៀនទី ១៖សេចក្តីស្រឡាញ់........................................ ៦
មេរៀនទី ២៖សេចក្តីអំណរ..........................................១០
មេរៀនទី ៣៖ភាពស្ងៀមស្ងាត់ ......................................១៣
មេរៀនទី ៤៖ សេចក្តីជំនឿ ..........................................១៦
មេរៀនទី ៥៖ការប្រុងស្តាប់ ..........................................១៩
មេរៀនទី ៦៖ការស្តាប់បង្គាប់ព្រះជាម្ចាស់ ......................... ២២
មេរៀនទី ៧៖ការគោរពនិងការចុះចូល.............................. ២៦
មេរៀនទី ៨៖ការបន្ទាបខ្លួន .......................................... ២៩
មេរៀនទី ៩៖ភាពរាបសា..............................................៣២
មេរៀនទី ១០៖ ភាពទៀងត្រង់........................................៣៥
មេរៀនទី ១១៖ ការលះបង់ខ្លួនឯងនិងការគិតអំពីអ្នកដទៃ .៣៨
មេរៀនទី ១២៖ ការស្កប់ចិត្ត..........................................៤១
មេរៀនទី ១៣៖ ភាពកត្តញ្ញូឬការដឹងគុណ .........................៤៤
មេរៀនទី ១៤៖ ការអត់ទោស ..........................................៤៨
មេរៀនទី ១៥៖ កំហឹង ..................................................៥១
មេរៀនទី ១៦៖ ភាពស្មោះត្រង់និងទំនួលខុសត្រូវ..............៥៤
មេរៀនទី ១៧៖ ភក្តីភាព................................................៥៧
មេរៀនទី ១៨៖ របៀបរៀបរយនិងវិន័យ ............................៦០
មេរៀនទី ១៩៖ ការអត់ធ្មត់និងការទ្រាំទ្រលំបាក ...............៦៣
មេរៀនទី ២០៖ សេចក្តីឧស្សាហ៍ និង ភាពឈ្លាសវៃ ...........៦៦
មេរៀនទី ២១៖ ប្រាជ្ញា(គតិបណ្ឌិត) ...................................៦៩


Copyright © Gratia Dei Sola Media

មេរៀនទី ២២៖ភាពបរិសុទ្ធផ្ទាល់ខ្លួន ..............................៧២
មេរៀនទី ២៣៖ការប្រមាណខ្លួនឬការទប់ចិត្តខ្លួនឯង.........៧៥
មេរៀនទី ២៤៖ការពោរពេញដោយសេចក្ដីអធិស្ឋាន.........៧៨
មេរៀនទី ២៥៖ការស្គាល់ខុសត្រូវ ..................................៨១

Copyright © Gratia Dei Sola Media

# អារម្ភកថា

ការទន្ទេញឱ្យចាំដែលចាត់ទុកជាទ្រឹស្តីនៃការទូន្មានមួយត្រូវបានគេរាប់ជាទ្រឹស្តីដ៏លំបាកបំផុត។

ប៉ុន្តែបទគម្ពីរបង្រៀនយើងយ៉ាងច្បាស់ថា យើងមិនត្រូវតែ "នឹកចាំអស់ទាំងពាក្យត្រឹមត្រូវ" (២ធីម៉ូថេ ១:១៣) ប៉ុណ្ណោះទេ តែគឺត្រូវចងចាំបទគម្ពីរផង ត្បិតព្រះបាទដាវីឌបានសរសេរទុកថា "ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឱ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ"(ទំនុកដម្កើង ១១៩:១១)។

ជាងនេះទៅទៀតបទពិសោធន៍របស់យើង បង្រៀនយើងថាកិច្ចការដែលយើងប្តេជ្ញាថាទន្ទេញឱ្យចាំកាលពីនៅកុមារភាព គឺជាការចងចាំដែលនៅជាប់យូរជាងគេក្នុងជីវិតរបស់យើង រហូតដល់ថ្ងៃស្លាប់។

ដោយហេតុនេះហើយបានជាថ្នាក់រៀនពីគោលជំនឿនៅឯព្រះវិហារPilgrim Convenant Church (PCC)។

ក៏ដូចជាពួកជំនុំកែរទម្រង់ដែលល្អជាងគេ សង្កត់ធ្ងន់ទៅលើការសិក្សាដោយទន្ទេញឱ្យចាំ។ ពិតណាស់យើងចង់ធានា ឱ្យបានថា កូនចៅរបស់យើងយល់ពីអ្វីដែលគេទន្ទេញ ដរាបណា យើងនៅតែអាចធ្វើបាន។

ប៉ុន្តែកត្តាសំខាន់គឺថា សមត្ថភាពចងចាំរបស់ក្មេង គឺច្រើនតែលើសពីសមត្ថភាពនៃការយល់ដឹងរបស់វា (គឺដូចជាសមត្ថភាពនៃការអានរបស់វាធម្មតាច្រើន ទៅមុនសមត្ថភាពនៃការយល់ របស់វា)។ ដូច្នេះយើងនឹងព្យាយាមឱ្យលើកទឹកចិត្ត និងបង្ហាត់ពួក គេឱ្យ

Copyright © Gratia Dei Sola Media

ចងចាំឱ្យបានឆាប់ ទៅតាមសមត្ថភាពរបស់ពួកគេទាំងដឹង យ៉ាងច្បាស់ថា គោលជំនឿ និងខគម្ពីរដែលគេទន្ទេញចាំពេល នៅក្មេងនឹងនៅជាប់តែនឹងសម្បកក្រៅនៃចិត្តពួកគេប៉ុណ្ណោះ។ យើងក៏ជឿដែរថា ពេលដែលព្រះជាម្ចាស់ចាប់ផ្តើមធ្វើការដោយព្រះ គុណនៅក្នុងចិត្តរបស់ពួកគេ (ដែលអាចកើតមានតាំងពីនៅក្មេង) ពាក្យទាំងនោះនៅជាប់ក្នុងការចងចាំរបស់ពួកគេ ហើយពាក្យ នេះនឹងលិចចុះទៅយ៉ាងជ្រៅដូចជាថ្មដែលជាប់លើផ្ទៃបឹងទឹកកក ដែលលិចចុះទៅក្នុងទឹក ខណៈពេលដែលពន្លឺថ្ងៃរះនានាទិយរដូវ ដោយរំលាយផ្ទៃទឹកកកខាងលើ។

តើព្រះយេស៊ូវមិនបានបង្រៀនយើងថា តួនាទីមួយនៃព្រះវិញ្ញាណ គឺត្រូវរំឭកគ្រប់សេចក្តីដែលយើងបានរៀនទេឬអី (យ៉ូហាន ១៤:២៦)?

កូនសៀវភៅថ្មីដែលមានចំណងជើងថា ការកសាងចរិកលក្ខណៈនេះ ត្រូវបានរៀបរៀងឡើងសម្រាប់ការប្រើប្រាស់ ក្នុងថ្នាក់បឋមទី៣ និងទី៤ (ក្រោយពីគេបានបញ្ចប់ការសិក្សា សៀវភៅគោលជំនឿស្តីពីប្រវត្តិព្រះគម្ពីរ ទាំងពីរកម្រិតរួច)។

ធម្មតាការកសាងចរិកលក្ខណៈមិនមែនអាចបង្រៀន យ៉ាងស្រួលតាមការទន្ទេញចាំនោះទេ។

ប៉ុន្តែខគម្ពីរទាំងនេះនឹងផ្តល់នូវគ្រឹះយ៉ាងល្អ ដល់កូនៗរបស់យើងខណៈ ដែលពួកគេធ្វើការកសាងចរិកលក្ខណៈរបស់ពួកគេតាមរយៈបទពិសោធន៍ និងការអនុវត្តព្រះបន្ទូលព្រះ។ យើងសូមណែនាំឱ្យក្មេងៗ យ៉ាងហោចណាស់ទន្ទេញឱ្យចាំនូវចម្លើយរបស់សំនួរ (អត្ថបទដែលនៅខាងមុខសញ្ញាត្រេ) ហើយបើសិន ជាគេ

Copyright © Gratia Dei Sola Media

អាចទន្ទេញខគម្ពីរទាំងនោះបានទៀត គឺរឹតតែល្អតែវាអាស្រ័យលើការសម្រេចចិត្តរបស់ឪពុកម្ដាយគេ។

ឪពុកម្ដាយ (ជាពិសេសឪពុក) ចូរព្យាយាមចំណាយពេលវេលាពន្យល់ខគម្ពីរ ក៏ដូចជាចែកចាយបទពិសោធន៍ទាក់ទងខ្លះដើម្បីជាប្រយោជន៍ដល់កូនៗឱ្យគេយល់ ព្រមទាំងអនុវត្តខគម្ពីរនោះក្នុងជីវិតរបស់គេផ្ទាល់ ។

ជាងនេះទៀត ខ្ញុំសូមណែនាំឱ្យគូសបង្ហាញខគម្ពីរនោះនៅលើព្រះគម្ពីររបស់ក្មេងនោះផ្ទាល់។ ដើម្បីការពារពេលណាបើក្មេងនោះភ្លេចខយោងសម្រាប់មេរៀនដែលគេបានសិក្សាហើយ ដោយយថាហេតុ គេនឹងអាចរកឃើញខនោះពីក្នុងព្រះគម្ពីររបស់គេផ្ទាល់ដោយមិនពិបាក។

គ្រូបង្រៀនថ្នាក់គោលជំនឿ អំពីថ្ងៃឈប់សម្រាក គួរត្រូវបានគេមើលឃើញថាជាការបន្ថែមការកំសាន្ត ដល់កុមារទៅលើការផ្ដល់ដំបូន្មានដល់ក្មេងៗ។ ពួកគាត់ប្រាកដជានឹងព្យាយាម ពង្រឹងមេរៀនមួយចំនួន តែគេក៏ត្រូវឱ្យក្មេងៗចំណាយពេលពី ភាគ្យាអ្វីដែលគេបានរៀនដែរ។ ពួកគាត់ក៏នឹងរំឭកខគម្ពីរទាំងអស់នេះជាមួយនឹងកូនៗរបស់អ្នកដោយឱ្យឡើងសូត្រម្ដងម្នាក់ៗ។ ខ្ញុំក៏សូមណែនាំឱ្យក្មេងៗសរសេរ (ដោយមានការមើលខុសត្រូវ ពីឪពុកម្ដាយ) រឿងដែលមានត្រឹមមួយរយពាក្យ ដោយយោងតាមប្រធានបទនៃមេរៀនសម្រាប់សប្ដាហ៍បន្ទាប់ទុកជាលំហាត់បន្ថែម។

ប៉ុន្តែ គ្រូបង្រៀនត្រូវរៀនប្រុងប្រយ័ត្នក្នុងការដាក់លំហាត់ការងារដទៃៗទៀត។ ពិតណាស់ឪពុកម្ដាយ និងគ្រូបង្រៀន ត្រូវបានលើកទឹកចិត្តឱ្យរៀន សម្រេចចិត្តលើបទដ្ឋានមួយដែលបាន

Copyright © Gratia Dei Sola Media

រៀបចំសម្រាប់ក្មេងម្នាក់ៗ។ ខណៈពេលដែលក្មេងនោះ ចម្រើនវ័យឡើងទៅកម្រិតមួយផ្សេង ការទាមទារឱ្យទន្ទេញឱ្យចាំនូវខគម្ពីរពេញមួយទំព័រ អាចជាការពិបាកសម្រាប់ក្មេងមួយចំនួន។ ប្រសិនបើមានករណីនេះកើតឡើងចំពោះកូនរបស់អ្នក ចូរបង្ហាញប្រាប់គ្រូបង្រៀនថា ខគម្ពីរណាខ្លះដែលគេចាំ ដើម្បីឱ្យគ្រូនោះរំឭកតែខគម្ពីរដែលកូនរបស់អ្នកចាំបានហើយ។

ដូចគ្នាដែរ ការសរសេររឿងក៏ប្រហែលជាការលំបាកសម្រាប់ក្មេងខ្លះដែរ។ មិនថាមានករណីអ្វីកើតឡើងទេយើងត្រូវស្វះស្វែងបង្កើតនូវបទពិសោធន៍រៀន និងធ្វើឱ្យមេរៀននោះមានខ្លឹមសារមិនត្រូវគេចចេញទេ។ សូមព្រះអម្ចាស់ប្រទានពរដល់កិច្ចខិតខំប្រឹងប្រែងរបស់យើង ហើយដោយព្រោះព្រះវិញ្ញាណបរិសុទ្ធ សូមឱ្យព្រះបន្ទូលដែលបានចងចាំ និងបានទទួលយកបានរួមគ្នា ជាមួយនឹងសេចក្តីជំនឿនៅក្នុងចិត្តរបស់កូនៗ ដើម្បីឱ្យគេអាចបង្កើតផលផ្លែ សម្រាប់ថ្វាយសិរីល្អដល់ព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់។

**លោកគ្រូគង្វាល ជេ. ជេ. លិម**

ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២; ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥

Copyright © Gratia Dei Sola Media

# មេរៀនទី ១
# សេចក្ដីស្រឡាញ់

## ១.១. តើបញ្ញត្តិណាមួយដែលសំខាន់ជាងគេ?

ត្រូវឱ្យស្រឡាញ់ព្រះទាំងស្រុង "ឯបញ្ញត្តិទីមួយនោះគឺថាចូរស្ដាប់ចុះអ៊ីស្រាអែលអើយ ព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ ទ្រង់ជាព្រះអម្ចាស់តែមួយព្រះអង្គទ្រង់ ហើយឯងត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ជាព្រះនៃឯង ឱ្យអស់ពីចិត្ត អស់ពីព្រលឹងអស់ពីគំនិតនិងអស់ពីកម្លាំងឯង" នោះហើយជាបញ្ញត្តិទី១។ (ម៉ាកុស ១២:២៩-៣០)

## ១.២. ចុះបញ្ញត្តិសំខាន់ជាងគេទីពីរ?

ត្រូវឱ្យស្រឡាញ់អ្នកដទៃដូចខ្លួនឯង"ឯបញ្ញត្តិទីពីរក៏បែបដូចគ្នាគឺ "ត្រូវឱ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង" គ្មានបញ្ញត្តិណាទៀតធំជាងបទទាំងពីរនេះទេ (ម៉ាកុស ១២:២៩-៣១)។

## ១.៣. តើបញ្ញត្តិថ្មីគឺជាអ្វី?

ត្រូវឱ្យស្រឡាញ់បងប្អូនរួមជំនឿ ដូចព្រះគ្រីស្ទស្រឡាញ់យើង "ខ្ញុំឱ្យសេចក្ដីបញ្ញត្តិមួយថ្មីដល់អ្នករាល់គ្នា គឺត្រូវឱ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមកដែរ ត្រូវឱ្យស្រឡាញ់គ្នាដូចជាខ្ញុំស្រឡាញ់អ្នករាល់គ្នាដែរ គេនឹងដឹងថាអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីនេះឯងគឺដោយអ្នករាល់គ្នាមាន សេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក"។ (យ៉ូហាន ១៣:៣៤-៣៥)


Copyright © Gratia Dei Sola Media

## ១.៤. តើសេចក្ដីស្រឡាញ់ជាគុណធម៌ដ៏សំខាន់មែនទេ?

មែន បើគ្មានការស្រឡាញ់ទេ នោះខ្ញុំក៏មិនមែនជាអ្វីទាំងអស់ "បើខ្ញុំមានគ្រប់ទាំងសេចក្ដីជំនឿល្មមនឹងឱ្យភ្នំរើចេញបាន តែគ្មានសេចក្ដីស្រឡាញ់ទេ នោះខ្ញុំមិនជាអ្វីទេបើខ្ញុំចែកអស់ទាំងទ្រព្យសម្បត្តិ ខ្ញុំជាអាហារដល់គេ ហើយបើខ្ញុំប្រគល់រូបកាយខ្ញុំទៅឱ្យគេដុតតែគ្មានសេចក្ដីស្រឡាញ់ នោះគ្មានប្រយោជន៍ដល់ខ្ញុំសោះ។ "(១កូរិនថូស ១៣:២-៣)

## ១.៥. តើអ្នកត្រូវស្រឡាញ់អ្នកណាខ្លះ?

ត្រូវស្រឡាញ់មនុស្សគ្រប់គ្នា និងសត្រូវរបស់ខ្លួនផង "ប៉ុន្តែខ្ញុំប្រាប់ថាត្រូវស្រឡាញ់ខ្មាំងសត្រូវ ត្រូវឱ្យពរដល់អ្នកណាដែលប្រទេចផ្ដាសាអ្នក ត្រូវប្រព្រឹត្តល្អនឹងអ្នកណាដែលស្អប់អ្នករាល់គ្នា ហើយត្រូវអធិស្ឋានឱ្យអ្នកដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នាវិញ"។ (ម៉ាថាយ ៥:៤៤)

## ១.៦. តើអ្នកត្រូវរៀនពីវិធីស្រឡាញ់តាមអ្នកណា?

តាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលជាគំរូដ៏អស្ចារ្យនៃសេចក្ដីស្រឡាញ់ "ដោយសារសេចក្ដីនេះ យើងរាល់គ្នាបានស្គាល់សេចក្ដីស្រឡាញ់ គឺដោយទ្រង់បានស៊ូប្ដូរបង់ព្រះជន្មជំនួសយើង ដូច្នេះគួរឱ្យយើងប្ដូរជីវិតយើងជំនួសបងប្អូនផងដែរ"។ (១យ៉ូហាន ៣:១៦)

Copyright © Gratia Dei Sola Media

## ១.៧. តើអ្នកត្រូវស្រឡាញ់ដោយរបៀបណា?

ដោយពាក្យសម្ដី និងការប្រព្រឹត្ត "បើអ្នកណាមានភោគសម្បត្តិរបស់លោកិយនេះ ហើយឃើញបងប្អូនណាដែលខ្វះខាតតែមិនចេះអាណិតមេត្តាសោះ នោះធ្វើយ៉ាងម៉េចទើបឱ្យសេចក្ដីស្រឡាញ់នៃព្រះបានស្ថិតស្ថេរក្នុងអ្នកនោះបាន"។ (១យ៉ូហាន ៣:១៧-១៨)។

## ១.៨. ប្រហែលមកពីអ្នកមិនចូលចិត្តបងប្អូនណាម្នាក់នៅក្នុងពួកជំនុំហើយមើលទៅ?

មិនមែនទេ ខ្ញុំត្រូវស្រឡាញ់បងប្អូនគ្រប់ៗគ្នា "បើអ្នកណាថាខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូនវិញ អ្នកនោះជាអ្នកកុហក ត្បិតអ្នកណាដែលមិនស្រឡាញ់បងប្អូន ដែលបានមើលឃើញទៅហើយ នោះធ្វើម្ដេចឡើយឱ្យស្រឡាញ់ដល់ព្រះដែលមើលមិនឃើញទៅបាន។ (១យ៉ូហាន ៤:២០)

## ១.៩. ចុះបើមានបងប្អូនណាម្នាក់ធ្វើឱ្យអ្នកក្ដៅក្រហាយ តើអ្នកនៅតែត្រូវស្រឡាញ់គេឬ?

ពិតមែនហើយ សេចក្ដីស្រឡាញ់គ្របបាំងអំពើបាបជាអនេកអនន្ត "តែមុនបង្អស់ ត្រូវឱ្យអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់គ្នាឱ្យអស់ពីចិត្ត ត្បិតសេចក្ដីស្រឡាញ់នឹងគ្របបាំងអំពើបាបជាអនេកអនន្ត។ (១ពេត្រុស ៤:៨)


Copyright © Gratia Dei Sola Media

**១.១០.ដូច្នេះ មានន័យថាសេចក្តីស្រឡាញ់ងងឹតងងុលមែនទេ?**

មិនមែនទេ "(សេចក្តីស្រឡាញ់) មិនដែលអរសប្បាយនឹងសេចក្តីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្តីស្មោះត្រង់វិញ"។ (១កូរិនថូស ១៣:៦, លេវីវិន័យ ១៩:១៧)

# មេរៀនទី ២
# សេចក្តីអំណរ

## ២.១. តើអ្នកណាខ្លះដែលត្រូវមានអំណរ?

គ្រីស្ទបរិស័ទគ្រប់គ្នា ត្រូវតែមានអំណរ "ឱមនុស្សសុចរិតរាល់គ្នាអើយ ចូរមានចិត្តសប្បាយ ហើយរីករាយឡើងក្នុងព្រះយេហូវ៉ាចុះ អស់អ្នកដែលមានចិត្តទៀងត្រង់អើយ ចូរនាំគ្នាស្រែកឡើងដោយអំណរចុះ (ទំនុកដម្កើង ៣២:១១)។

## ២.២. តើយើងត្រូវមានអំណរនៅពេលណា?

រាល់ពេលរាល់វេលា "ចូរអរសប្បាយក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្តងទៀតថា ចូរអរសប្បាយឡើង" (ភីលីព៤:៤)។

## ២.៣. តើសេចក្តីអំណរពិតអាចរកបាននៅកន្លែងណា?

នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ "ទ្រង់នឹងបង្ហាញឱ្យទូលបង្គំឃើញផ្លូវជីវិតវិញ នៅចំពោះទ្រង់ ទូលបង្គំមានសេចក្តីអំណរដ៏ពោរពេញ នៅព្រះហស្តស្តាំទ្រង់ដែលមានសេចក្តីអរសប្បាយជាដរាបតទៅ" (ទំនុកដម្កើង ១៦:១១)។

## ២.៤. ហេតុអ្វីបានអ្នកត្រូវមានសេចក្តីអំណរ?

ខ្ញុំត្រូវមានសេចក្តីអំណរ ពីព្រោះតែខ្ញុំដឹងថាព្រះជាម្ចាស់បានសង្គ្រោះយើង "ខ្ញុំនឹងអរសប្បាយចំពោះព្រះយេហូវ៉ា ព្រលឹងខ្ញុំនឹងរីករាយចំពោះព្រះនៃខ្ញុំ ពីព្រោះទ្រង់បានប្រដាប់ខ្លួនខ្ញុំដោយសម្លៀកបំពាក់នៃសេចក្តីសុចរិត..."។

(អេសាយ ៦១:១០, រ៉ូម ៥:១១)

 Copyright © Gratia Dei Sola Media

**២.៥. តើអ្នកត្រូវមានឥរិយាបទបែបណាដើម្បីឱ្យមានសេចក្តីអំណរ?**

ខ្ញុំត្រូវមានចិត្តរាបសារ និងត្រូវបន្ទាបខ្លួន "មនុស្សរាបសានឹងមានសេចក្តីអំណរ ចម្រើនឡើងក្នុងព្រះយេហូវ៉ា ហើយពួកអ្នកក្រីក្រក្នុងបណ្តាមនុស្ស គេនឹងរីករាយដោយសារតែព្រះដ៏បរិសុទ្ធ គេនឹងរីករាយដោយសារព្រះដ៏បរិសុទ្ធរបស់អ៊ីស្រាអែល"។ (អេសាយ ២៩:១៩)

**២.៦. ចុះបើអ្នកត្រូវឆ្លងកាត់ការលំបាកតើអ្នកអាចមានអំណរទេ?**

មែនហើយ ត្បិតព្រះជាម្ចាស់កំពុងធ្វើការដោយព្រះគុណនៅក្នុងអ្នក "បងប្អូនអើយកាលណាអ្នករាល់គ្នាមានសេចក្តីល្បួងផ្សេងៗ នោះត្រូវរាប់ជាសេចក្តីអំណរសព្វគ្រប់វិញ ដោយដឹងថាការល្បួងលមើល សេចក្តីជំនឿនៃអ្នករាល់គ្នានោះនាំបង្កើតឱ្យមានសេចក្តីខ្ជាប់ខ្ជួន"។

(យ៉ាកុប ១:២-៤, ១ពេត្រុស ១:៦)។

**២.៧. អ្នកជិតខាងរបស់អ្នករកឃើញការអរសប្បាយនៅក្នុងកិច្ចការលោកិយ តើអ្នកគួរចូលរួមនឹងគេដែរមែនទេ?**

ទេ! ប្រសិនបើពួកគេធ្វើកិច្ចការណា មិនគាប់ដល់ព្រះហឫទ័យព្រះជាម្ចាស់ "ឱមនុស្សកម្លោះអើយ ចូរឱ្យមានចិត្តរីករាយក្នុងវ័យកម្លោះរបស់ឯងចុះ ហើយឱ្យចិត្តឯងបណ្តាលឱ្យអរសប្បាយក្នុងជំនាន់ដែលឯងនៅក្នុងផង ចូរដើរតាមផ្លូវនៃចិត្តឯង ហើយតាមតែភ្នែកឯងមើលឃើញដែរ ប៉ុន្តែត្រូវឱ្យដឹងថា ព្រះទ្រង់នឹងហៅឯងមកជំនុំជម្រះ ដោយព្រោះអំពើទាំងនេះជាមិនខាន"។ (សាស្តា ១១:៩)

Copyright © Gratia Dei Sola Media

**២.៨. តើពាក្យអរសប្បាយមានន័យថា និយាយរឿងកំប្លែងលេង សើចមែនទេ?**

ការសើចសប្បាយនឹងរឿងកំប្លែង មិនមែនជាការខុសឆ្គងទេ ប៉ុន្តែ សេចក្ដីអំណរពិតត្រូវបានរកឃើញនៅក្នុងការដឹងគុណចំពោះព្រះអម្ចាស់ សម្រាប់គ្រប់កិច្ចការទាំងអស់ "ត្បិតសំណើចរបស់មនុស្សល្ងីល្ងើ នោះឮដូចជាសូរគុកគឹកពីបន្លាដែលឆេះក្រោមឆ្នាំង នេះក៏ជាការឥតប្រយោជន៍ទទេ"។ (សាស្ដា ៧:៦)។

**២.៩. តើអ្នកអាចអរសប្បាយពេលលេងសើចបានដែរឬទេ?**

ប្រាកដណាស់ខ្ញុំត្រូវដឹងគុណដល់ព្រះអម្ចាស់ ចំពោះភាពរីករាយដ៏ល្អ ហើយសមរម្យ "ចិត្តដែលសប្បាយជាថ្នាំយ៉ាងវិសេស តែវិញ្ញាណបាក់បែករមែងឱ្យឆ្អឹងរីងស្ងួតទៅ"។ (សុភាសិត ១៧:២២)។

**២.១០.តើធ្វើដូចម្ដេចឱ្យអ្នកមានសេចក្ដីអំណរបាននៅពេលណាដែលអ្នកមិនលេងសើច?**

ដោយ"ធ្វើគ្រប់ការទាំងអស់ ដោយឥតត្អូញត្អែរ ឥតប្រកែក"។ (ភីលីព ២:១៤)


Copyright © Gratia Dei Sola Media

# មេរៀនទី ៣
# ភាពស្ងៀមស្ងាត់

## ៣.១.តើព្រះជាម្ចាស់ឱ្យយើងមានភាពស្ងៀមស្ងាត់មែនទេ?

ពិតមែនហើយ ទ្រង់ជាព្រះនៃសេចក្ដីសុខសាន្ត ដូច្នេះទ្រង់ប្រាកដជាចង់ឱ្យយើងមានភាពស្ងៀមស្ងាត់ "ហេតុដូច្នេះត្រូវឱ្យយើងដេញតាមអស់ទាំងសេចក្ដីដែលនាំឱ្យមេត្រីគ្នា និងសេចក្ដីទាំងប៉ុន្មានជួយស្អាងចិត្តគ្នាទៅវិញទៅមកវិញ"។ (រ៉ូម ១៤:១៩)

## ៣.២.តើភាពស្ងៀមស្ងាត់មានន័យយ៉ាងដូចម្ដេច?

គឺត្រូវគេចចេញពីជម្លោះជាមួយនឹងនរណាម្នាក់ "តែប្រាជ្ញាដែលមកពីស្ថានលើ នោះមុនដំបូងហៅថា បរិសុទ្ធ រួចមកមានសេចក្ដីមេត្រីចិត្ត សេចក្ដីសម្លូត ចិត្តទន់ ក៏ពេញដោយសេចក្ដីមេត្តាករុណា និងផលល្អ ឥតរើសមុខ ហើយឥតពុតមាយាផង រីឯផលនៃសេចក្ដីសុចរិត នោះបានព្រោះចុះដោយសេចក្ដីមេត្រី សម្រាប់ពួកអ្នកដែលរកសេចក្ដីមេត្រីនោះឯង"។ (យ៉ាកុប ៣:១៧-១៨)

## ៣.៣.តើធ្វើដូចម្ដេចឱ្យអ្នកស្ងៀមស្ងាត់បាន បើមនុស្សដែលនៅជុំវិញអ្នកសុទ្ធតែជាមនុស្សបង្ករជម្លោះ?

ដរាបណាអ្នកស្ងៀមស្ងាត់គឺបានហើយ អ្នកមិនត្រូវខ្វល់នឹងអ្នកដទៃឡើយ "ខាងឯពួកអ្នករាល់គ្នា នោះឱ្យខំនៅជាមេត្រីនឹងមនុស្សទាំងអស់ចុះ បើសិនជាបាន"។ (រ៉ូម ១២:១៨)

Copyright © Gratia Dei Sola Media

## ៣.៤.បើមិត្តអ្នកឈ្លោះគ្នាជាមួយអ្នកដទៃតើអ្នកធ្វើយ៉ាងណា?

អ្នកអាចព្យាយាមធ្វើជាអ្នកផ្សះផ្សា "មានពរហើយអស់អ្នកដែលផ្សះផ្សាគេ ត្បិតអ្នកទាំងនោះនឹងបានហៅជាកូនព្រះ"។ (ម៉ាថាយ ៥:៩)។

## ៣.៥.តើអ្នកត្រូវអត់ធ្មត់ចំពោះនឹងអស់មនុស្សដែលរឹងទទឹងជាមួយអ្នកដូចម្តេចបាន?

ដោយចិត្តបន្ទាបខ្លួន និងចិត្តរាបសារ "ព្រមទាំងមានចិត្តសុភាព ហើយស្លូតបូតគ្រប់ជំពូក ទាំងអត់ធ្មត់ ហើយទ្រាំទ្រគ្នាទៅវិញទៅមកដោយស្រឡាញ់ ហើយខំប្រឹងរក្សាសេចក្តីរួបរួមគ្នារបស់ព្រះវិញ្ញាណ ដោយសេចក្តីមេត្រីទុកជាចំណងផង"។ (អេភេសូរ៤:២-៣, ២ធីម៉ូថេ ២:២៤-២៥)

## ៣.៦.តើវាសំខាន់ទេដែលអ្នកត្រូវតែស្ងៀមស្ងាត់ពេលនៅផ្ទះ?

មែនហើយ គ្រួសារគ្រីស្ទបរិស័ទត្រូវតែសៀមស្ងាត់ "បើមានតែបាយក្រៀមមួយដុំ ដែលនឹងបរិភោគដោយសេចក្តីសុខ នោះវិសេសជាងមានផ្ទះពេញដោយការជប់លៀង តែមានសេចក្តីទាស់ទែងគ្នាវិញ"។ (សុភាសិត ១៧:១)

## ៣.៧.តើសេចក្តីមេត្រីនៅក្នុងពួកជំនុំសំខាន់ដែរឬ?

ពិតណាស់ ព្រះជាម្ចាស់មានព្រះទ័យរីករាយ ពេលមានការរួបរួមនិងមានមេត្រីភាពនៅក្នុងពួកជំនុំ "មើលដែលបងប្អូននៅមូលជាមួយគ្នាដោយចិត្តព្រមព្រៀង នោះជាការល្អហើយសមគួរយ៉ាងណាទៅ"។ (ទំនុកដម្កើង ១៣៣:១)


Copyright © Gratia Dei Sola Media

## ៣.៨.តើអ្នកអាចផ្សព្វផ្សាយសេចក្តីមេត្រីនៅក្នុងពួកជំនុំបានយ៉ាងដូចម្តេច?

ដោយគេចចេញពីជម្លោះជាមួយនឹងមនុស្សគ្រប់គ្នា ទាំងអធិស្ឋានសុំភាពសុខសាន្ត "ចូរថយចេញពីការអាក្រក់ហើយប្រព្រឹត្តការល្អវិញ ចូរស្វែងរកសេចក្តីសុខ ហើយដេញជាប់តាមចុះ "(ទំនុកដម្កើង ៣៤:១៤) "ចូរអធិស្ឋានឱ្យក្រុងយេរូសាឡិមបានសេចក្តីសុខចុះ សូមឱ្យអស់អ្នកដែលស្រឡាញ់ឯងបានសេចក្តីចម្រើន" ។ (ទំនុកដម្កើង ១២២:៦)

Copyright © Gratia Dei Sola Media

# មេរៀនទី ៤
# សេចក្ដីជំនឿ

## ៤.១. តើអ្វីទៅជាសេចក្ដីជំនឿ?

សេចក្ដីជំនឿ គឺជាការជឿ "រីឯសេចក្ដីជំនឿ នោះគឺជាចិត្ត ដែលដឹងជាក់ថានឹងបានដូចសង្ឃឹម ជាសម្គាល់ពីការដែលមើលមិនឃើញ" (ហេព្រើរ ១១:១)។

## ៤.២. តើសេចក្ដីជំនឿសំខាន់ដែរឬ?

ពិតមែនហើយ បើសិនជាគ្មានជំនឿទេ យើងមិនផ្គាប់ព្រះទ័យព្រះជាម្ចាស់ឡើយ "តែបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះ បានឡើយត្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវជឿថាមានព្រះមែន ហើយថាទ្រង់ប្រទានរង្វាន់ដល់អស់អ្នកណាដែលស្វែងរកទ្រង់"។ (ហេព្រើរ ១១:៦)

## ៤.៣.តើសេចក្ដីជំនឿគឺជាសារជាតិដែលមនុស្សគ្រប់រូបមានតាំងពីកំនើតមែនទេ?

ទេ! ធម្មជាតិរបស់មនុស្សគ្មានសេចក្ដីជំនឿទេ"ពីដើមអ្នករាល់គ្នាស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដែរ... ត្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនេះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ"(អេភេសូរ ២:១, ៨)។


Copyright © Gratia Dei Sola Media

## ៤.៤. តើព្រះជាម្ចាស់ប្រទានសេចក្តីជំនឿដល់អ្នកណាខ្លះ?

អស់អ្នកដែលព្រះអង្គជ្រើសរើស "ចំណែកអស់អ្នកដែលត្រូវបានជីវិតអស់កល្បជានិច្ច នោះក៏បានជឿ" (កិច្ចការ ១៣:៤៨)។

## ៤.៥. សេចក្តីជំនឿគឺជាការជឿ ប៉ុន្តែតើអ្នកណាដែលយើងត្រូវជឿជាពិសេសនោះ?

យើងត្រូវតែជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ សម្រាប់សេចក្តីសង្គ្រោះ "យើងដឹងថា មនុស្សមិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឱ្យបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទនោះ មិនមែនដោយក្រឹត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិតដោយសារក្រិត្យវិន័យឡើយ"។ (កាឡាទី ២:១៦)

## ៤.៦. តើអ្នកអាចលូតលាស់នៅក្នុងសេចក្តីជំនឿយ៉ាងដូចម្តេច?

តាមរយៈការស្តាប់ព្រះបន្ទូលព្រះ និងការអធិស្ឋាន "ដូច្នេះសេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ" (រ៉ូម ១០:១៧) "ខ្ញុំជឿហើយលោកម្ចាស់អើយ សូមជួយចំពោះសេចក្តីណាដែលខ្ញុំមិនជឿផង"។ (ម៉ាកុស៩:២៤)

Copyright © Gratia Dei Sola Media

## ៤.៧.តើមានអ្នកជឿក្លែងក្លាយ ឬអ្នកក្លែងធ្វើជាជឿដែរមែនទេ?

ពិតជាមានច្រើននាក់ណាស់ នៅក្នុងលោកនេះ "ឯពួកអ្នកដែលទទួលនៅលើថ្ម គឺអស់អ្នកណាដែល កាលណាឮព្រះបន្ទូលហើយ នោះក៏ទទួលដោយអំណរ តែគ្មានចាក់ឫសសោះ គេជឿនៅតែមួយស្របក់ប៉ុណ្ណោះ លុះកើតមានសេចក្ដីល្បួង នោះគេរសាយចិត្តទៅវិញ"។ (លូកា៨:១៣, ម៉ាថាយ ១៣:២០-២១, កិច្ចការ ៨:១៣, ២០-២៣, កិច្ចកា ២៦:២៧-២៨)

## ៤.៨. តើសេចក្ដីជំនឿ ចាំបាច់នៅក្នុងសេចក្ដីអធិស្ឋានមែនទេ?

ពិតមែនហើយ ត្បិតព្រះជាម្ចាស់មិនឆ្លើយតបចំពោះសេចក្ដីអធិស្ឋានណា ដែលគ្មានសេចក្ដីជំនឿនោះទេ-"ហើយគ្រប់ទាំងសេចក្ដីអ្វី ដែលអ្នករាល់គ្នាអធិស្ឋានសូម ដោយមានចិត្តជឿ នោះនឹងបានសម្រេចទាំងអស់"។ (ម៉ាថាយ២១:២២)

## ៤.៩. តើសេចក្ដីជំនឿ ចាំបាច់សម្រាប់ជីវិតគ្រីស្ទបរិស័ទដែរឬទេ?

ពិតជាចាំបាច់ ត្បិតបើគ្មានសេចក្ដីជំនឿទេ យើងនឹងត្រូវលោកិយនេះបំផ្លាញអស់ជាមិនខាន "ឯជ័យជំនះដែលឈ្នះលោកិយនោះគឺជាសេចក្ដីជំនឿរបស់យើង តើអ្នកណាជាអ្នកឈ្នះលោកិយ? បើមិនមែនជាអ្នកដែលជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ"។ (១យ៉ូហាន៥:៤-៥)

 Copyright © Gratia Dei Sola Media

# មេរៀនទី ៥
# ការប្រុងស្តាប់

## ៥.១. តើយើងត្រូវគេបង្គាប់ឱ្យប្រុងស្តាប់មែនទេ (ប្រុងទាំងភ្នែក ប្រុងទាំងត្រចៀក និងប្រុងទាំងចិត្ត)?

មែនហើយ ព្រះបាទសាឡូម៉ូនបង្រៀនយើង ឱ្យប្រុងប្រយ័ត្ន "កូនអើយ ចូរប្រុងស្តាប់អស់ទាំងពាក្យរបស់អញ ហើយផ្ទៀងត្រចៀកស្តាប់សេចក្តីដែលអញបានពោល ទាំងអំបាលម៉ាន កុំឱ្យសេចក្តីទាំងនោះឃ្លាតបាត់ពីភ្នែកឯងឡើយ ត្រូវឱ្យរក្សាទុកកណ្តាលដួងចិត្តឯងវិញ"។ (សុភាសិត ៤:២០-២១)

## ៥.២. តើអ្នកអាចរៀនប្រុងស្តាប់ពីអ្នកណា?

រៀនពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលជាគំរូនៃការប្រុងស្តាប់ដ៏ល្អបំផុត "លុះកន្លងក្រោយមកបីថ្ងៃនោះ ទើបឃើញទ្រង់គង់នៅកណ្តាលពួកអាចារ្យក្នុងព្រះវិហារ កំពុងតែស្តាប់ហើយនិងសួរគេ"។ (លូកា២:៤៦)

## ៥.៣. តើយើងត្រូវប្រុងស្តាប់អ្នកណាជាពិសេស?

យើងត្រូវប្រុងស្តាប់ព្រះអម្ចាស់ ជាពិសេសព្រះអម្ចាស់មានព្រះបន្ទូលថា "ចៀមខ្ញុំទាំងប៉ុន្មាន វាស្តាប់ខ្ញុំហើយមកតាមខ្ញុំក៏ស្គាល់វាដែរ"។ (យ៉ូហាន១០:២៧, ៣-៤)

## ៥.៤. តើអ្នកអាចរៀនប្រុងស្តាប់ព្រះអម្ចាស់ដោយរបៀបណា?

ដោយស្តាប់ និងទទួលព្រះបន្ទូលព្រះជាម្ចាស់ដោយអំណរ "រីឯពួកស្រុកនោះ មានចិត្តល្អជាងពួកអ្នកនៅថែស្សាឡូនីច

Copyright © Gratia Dei Sola Media

គេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃ ឱ្យបានដឹងជាសេចក្តីទាំងនោះ ត្រូវឬមិនត្រូវ”។ (កិច្ចការ១៧:១១, ១ថែស្សាឡូនីច ២:១៣)

## ៥.៥. តើសំខាន់ដែរទេ ដែលត្រូវចេះត្រៀមមុនថ្លែងព្រះបន្ទូល?

ពិតជាសំខាន់ ត្បិត“សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ”។ (រ៉ូម១០:១៧)

## ៥.៦. ចុះបើអ្នកបានដឹងមុននូវអ្វីដែលគេកំពុងអធិប្បាយ ឬកំពុងបង្រៀន?

ខ្ញុំក៏នៅតែត្រូវប្រុងស្តាប់ ពីព្រោះជានិច្ចជាកាល វារមែងតែងមានរឿងរ៉ាវថ្មីៗជាច្រើន ដែលត្រូវរៀន ឬរំឭកឱ្យដឹង“បានជាអ្នកណាដែលស្មានថាខ្លួនឈរ នោះត្រូវប្រយ័ត្នក្រែងលោដួល”។ (១កូរិនថូស ១០:១២)

## ៥.៧. តើអ្នកត្រូវជឿលើអ្វីគ្រប់យ៉ាងដែលអ្នកស្តាប់ឮមែនទេ?

ទេ! ខ្ញុំត្រូវតែជឿលើអ្វីដែលស្របនឹងព្រះគម្ពីរ តែប៉ុណ្ណោះ “ចូរលមើលគ្រប់ទាំងអស់ ហើយកាន់ខ្ជាប់តាមសេចក្តីដែលត្រឹមត្រូវ”។ (១ថែស្សាឡូនីច ៥:២១)

## ៥.៨. តើមានអ្វីកើតឡើង ពេលអ្នកមិនបានប្រុងប្រយ័ត្ន?

ពេលខ្ញុំមិនបានប្រុងប្រយ័ត្ន នោះខ្ញុំនឹងមិនបានទទួលព្រះពរពីព្រះជាម្ចាស់ទាល់តែសោះ “ដូច្នេះ ត្រូវឱ្យប្រយ័ត្នដែលអ្នករាល់គ្នាឮជាយ៉ាងណា ត្បិតអ្នកណាដែលមាន គេនឹងឱ្យ


Copyright © Gratia Dei Sola Media

ដល់អ្នកនោះ ប៉ុន្តែអ្នកណាដែលគ្មាន នោះនឹងដកយកទាំងរបស់ដែលមើលទៅដូចជាអ្នកនោះមានចេញផង"។ (លូកា ៨:១៨)

**៥.៩. តើអ្នកអាចរៀនប្រុងស្ដាប់អ្នកដទៃបានដោយរបៀបណា?**

ដោយឆាប់ស្ដាប់ ក្រនឹងនិយាយ "ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ ចូរឱ្យគ្រប់គ្នាឆាប់នឹងស្ដាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ"។ (យ៉ាកុប ១:១៩)

Copyright © Gratia Dei Sola Media 

# មេរៀនទី ៦
# ការស្ដាប់បង្គាប់ព្រះជាម្ចាស់

## ៦.១. តើការស្ដាប់បង្គាប់ព្រះជាម្ចាស់ត្រូវបានបង្គាប់ក្នុងព្រះគម្ពីរមែនទេ?

មែនហើយ ការស្ដាប់បង្គាប់ព្រះជាម្ចាស់ ត្រូវបានបង្គាប់គ្រប់ពាក្យក្នុងព្រះគម្ពីរឧទាហរណ៍ "ត្រូវឱ្យដើរតាមតែព្រះយេហូវ៉ាជាព្រះនៃឯងវិញ ហើយកោតខ្លាចដល់ទ្រង់ព្រមទាំងកាន់តាមសេចក្ដីបញ្ញាត្តិទាំងប៉ុន្មានរបស់ទ្រង់ និងស្ដាប់តាមព្រះបន្ទូលទ្រង់ ក៏ត្រូវគោរពប្រតិបត្តិដល់ទ្រង់ ហើយនៅជាប់នឹងទ្រង់ផង"។ (ចោទិយកថា ១៣:៤, សាស្ដា ១២:១៣)

## ៦.២. តើគ្រីស្ទបរិស័ទត្រូវស្ដាប់បង្គាប់ព្រះជាម្ចាស់ ច្រើនជាមនុស្សដទៃទៀតនៅលើលោកិយមែនទេ?

មែនហើយ ក្នុងនាមជាប្រជារាស្ត្ររបស់ព្រះ យើងត្រូវស្ដាប់តាមព្រះអង្គជាពិសេស "ដូច្នេះបើឯងរាល់គ្នាស្ដាប់តាមអញឥឡូវ ហើយកាន់តាមសេចក្ដីសញ្ញារបស់អញ នោះឯងរាល់គ្នានឹងបានដាច់ជារបស់ផងអញ លើសជាអស់ទាំងសាសន៍ត្បិតផែនដីទាំងមូលជារបស់ផងអញ"។
(និក្ខមនំ ១៩:៥, ចោទិយកថា ៧:៩)

 Copyright © Gratia Dei Sola Media

## ៦.៣. ប៉ុន្តែ ហេតុអ្វីបានជាគ្រីស្ទបរិស័ទត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ជាពិសេស?

គ្រីស្ទបរិស័ទត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ជាពិសេស ដោយចេញពីការដឹងគុណ និងដោយក្តីស្រឡាញ់ចំពោះព្រះអង្គក្នុងការដែលព្រះអង្គសង្គ្រោះយើងក្នុងព្រះគ្រីស្ទ "តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះដើម្បីឱ្យអ្នករាល់គ្នាបានសម្តែងចេញឱ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺដ៏អស្ចារ្យរបស់ទ្រង់ ពីដើមអ្នករាល់គ្នាមិនមែនជាសាសន៍ណាមួយទេ តែឥឡូវជាសាសន៍រព្រះវិញ ពីដើមមិនបានទទួលសេចក្តីមេត្តាករុណាទេ តែឥឡូវនេះបានទទួលហើយ"។
(១ពេត្រុស២:៩-១០,២:៥, ១កូរិនថូស ៦:១៩-២០, រ៉ូម ៦:១៣ និង១២:១-២)

## ៦.៤. តើអ្នករាល់គ្នាអាចរៀនស្តាប់បង្គាប់ពីអ្នកណា?

ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាពិសេស "ហើយទោះបើទ្រង់ជាព្រះរាជបុត្រាក៏ដោយ គង់តែទ្រង់បានរៀនស្តាប់បង្គាប់ដោយសារការដែលទ្រង់រងទុក្ខលំបាកទាំងប៉ុន្មាននោះដែរ"។
(ហេព្រើរ ៥:៨)

## ៦.៥. តើការស្តាប់បង្គាប់ពិតជាសំខាន់មែនទេ?

មែនហើយ ការស្តាប់បង្គាប់សំខាន់ជាងអ្វីៗទាំងអស់ ក្នុងការថ្វាយបង្គំខាងសាសនា "សាំយ៉ូអែលទូលឆ្លើយថា តើព្រះ

យេហូវ៉ាទ្រង់សព្វព្រះទ័យនឹងដង្វាយដុត ហើយនិងយញ្ញបូជាឱ្យស្មើរនឹងការស្តាប់តាមទ្រង់ឬអី? មើលដែលស្តាប់បង្គាប់នោះវិសេសជាងយញ្ញបូជា ហើយដែលផ្ទៀងត្រចៀកនោះក៏វិសេសជាខ្លាញ់នៃចៀមឈ្មោលទៅទៀត"។ (១សាំយ៉ូអែល ១៥:២២)

## ៦.៦. តើមានរឿងអ្វីកើតឡើង បើសិនជាអ្នកមិនគោរពក្រិត្យវិន័យរបស់ព្រះ?

សេចក្តីអធិស្ឋានរបស់អ្នកនឹងក្លាយជាទីស្អប់ខ្ពើម ដល់ព្រះជាម្ចាស់ "អ្នកណាដែលបែរត្រចៀកចេញ មិនព្រមស្តាប់បញ្ញាត្តិច្បាប់នោះទោះពាក្យអធិស្ឋានរបស់អ្នកនោះ ក៏ជាទីស្អប់ខ្ពើមដែរ"។ (សុភាសិត ២៨:៩)

## ៦.៧. តើអ្នកអាចជ្រើសយកការស្តាប់តាមបញ្ញាត្តិមួយចំនួន ហើយចោលមួយចំនួនផ្សេងទៀតបានទេ?

ទេ! អ្នកត្រូវស្តាប់តាមគ្រប់បទបញ្ញាត្តិ ដោយអំណរទាំងមានជំនួយពីព្រះអម្ចាស់"ដូច្នេះ ត្រូវឱ្យប្រយ័ត្ននឹងធ្វើដូចជាព្រះយេហូវ៉ាជាព្រះនៃឯងបានបង្គាប់មក កុំឱ្យងាកបែរទៅចេញទៅខាងស្តាំ ឬខាងឆ្វេងឡើយ"។ (ចោទិយកថា៥:៣២)

## ៦.៨. តើអ្នកត្រូវធ្វើអ្វីខ្លះ បើសិនជាអ្នកប្រាថ្នាចង់ស្តាប់តាមព្រះជាម្ចាស់ច្រើនជាងនេះ?

អ្នកត្រូវតែអធិស្ឋានសុំព្រះគុណថែមទៀត។ អ្នកត្រូវអធិស្ឋានដូចជាអ្នកសរសេរបទទំនុកដម្កើង "សូមប្រទានឱ្យទូលបង្គំ


Copyright © Gratia Dei Sola Media

មានយោបល់ នោះទូលបង្គំនឹងកាន់តាមក្រិត្យវិន័យទ្រង់ អើ ទូលបង្គំនឹងរក្សាទុកឱ្យអស់ពីចិត្តផង"។ (ទំនុកដម្កើង១១៩:៣៤, ១៤៣:១០)

## ៦.៩. តើអ្នកមានសេចក្ដីជំនឿ ដោយគ្មានការស្ដាប់បង្គាប់បានទេ?

ទេ! មិនអាចទេ សេចក្ដីជំនឿដែលគ្មានការស្ដាប់បង្គាប់ ជាសេចក្ដីជំនឿស្លាប់ "ចូរឱ្យអ្នករាល់គ្នាប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឱ្យគ្រាន់តែស្ដាប់ប៉ុណ្ណោះ ហើយបញ្ឆោតខ្លួនវិញនោះឡើយ"។ (យ៉ាកុប១:២២,២៥)

## ៦.១០.តើអ្នកអាចស្រឡាញ់ព្រះជាម្ចាស់ ដោយមិនស្ដាប់បង្គាប់ទ្រង់បានទេ?

ទេ! មិនអាចទេ ស្រឡាញ់ព្រះជាម្ចាស់មានន័យថា កាន់តាមបញ្ញាត្តិរបស់ទ្រង់"ត្បិតនេះ ហើយជាសេចក្ដីស្រឡាញ់ដល់ព្រះជាម្ចាស់ គឺឱ្យយើងកាន់តាមបញ្ញាត្តិទាំងអស់ របស់ទ្រង់ឯបញ្ញាត្តិទ្រង់ នោះមិនមែនជាបន្ទុកធ្ងន់ទេ"។ (១យ៉ូហាន ៥:៣, យ៉ូហាន ១៤:១៥)

Copyright © Gratia Dei Sola Media

# មេរៀនទី ៧
# ការគោរព និង ការចុះចូល

## ៧.១. តើការគោរពរដ្ឋអំណាច បានបង្គាប់ពីក្នុងព្រះគម្ពីរមែនទេ?

ពិតមែនហើយ ការនេះត្រូវបានបង្រៀននៅក្នុងបញ្ញាត្តិទីប្រាំ "ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់ មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ត្បិតធ្វើដូច្នោះទើបបានត្រូវ ចូរគោរពប្រតិបត្តិដល់មាតាបិតាខ្លួន នេះជាបញ្ញាត្តិមុនដំបូង ដែលជាប់មានទាំងសេចក្ដីសន្យាផង"។ (អេភេសូរ៦:១-២, និក្ខមនំ ២០:១២)

## ៧.២. តើអ្នកអាចរៀនគោរពពីអ្នកណា?

រៀនពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាពិសេស"ទ្រង់ក៏ចុះទៅឯភូមិណាសារ៉ែត ជាមួយនឹងគាត់វិញ ហើយបាននៅក្នុងឱវាទគាត់"។ (លូកា ២:៥១)

## ៧.៣.តើអ្នកត្រូវស្ដាប់បង្គាប់ឪពុកម្ដាយអ្នកក្នុងផ្នែកណាខ្លះ?

គ្រប់ផ្នែកទាំងអស់ "ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់ឪពុកម្ដាយក្នុងគ្រប់ការទាំងអស់ ត្បិតព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យយ៉ាងដូច្នោះឯង"។ (កូល៉ុស៣:២០, សុភាសិត ១:៨)

## ៧.៤. តើព្រះគម្ពីរនិយាយដូចម្ដេចអំពីការតមាត់ចំពោះឪពុកម្ដាយ?

វាជាការស្អប់ខ្ពើមចំពោះព្រះជាម្ចាស់យ៉ាងខ្លាំង "ឯភ្នែកដែលចំអកឱ្យឪពុក ហើយប្រមាថ មើលងាយមិនស្ដាប់បង្គាប់ម្ដាយនោះក្អែកនៅច្រកភ្នំនឹងចឹកភ្នែកនោះចេញ ហើយត្មាតនឹងជញ្ជែងស៊ីទៅ"។ (សុភាសិត ៣០:១៧)

 Copyright © Gratia Dei Sola Media

## ៧.៥. តើអ្នកត្រូវគោរពពួកចាស់ទុំ ឬព័ន្ធការីក្នុងពួកជំនុំដែរមែនទេ?

ពិតមែនហើយ ព្រះគម្ពីរបង្រៀនយើងឱ្យគោរពពួកគាត់ "ចូរស្ដាប់តាម ហើយចុះចូលនឹងពួកអ្នកដែលនាំមុខអ្នករាល់គ្នាចុះ ដើម្បីឱ្យពួកអ្នកទាំងនោះ បានថែរក្សាព្រលឹងអ្នករាល់គ្នាដោយអំណរ មិនមែនដោយស្រែកថ្ងូរទេ ត្បិតបើត្រូវស្រែកថ្ងូរ នោះបង់ប្រយោជន៍ដល់អ្នករាល់គ្នាហើយ ពីព្រោះតែអ្នកទាំងនោះថែរក្សាហាក់ដូចជានឹងត្រូវទូលដល់ទ្រង់វិញ"។ (ហេព្រើរ ១៣:១៧)

## ៧.៦. តើអ្នកត្រូវគោរពរដ្ឋាភិបាលនៃប្រទេសរបស់អ្នកដែរមែនទេ?

មែនហើយ ទោះបើអ្នកដឹកនាំទាំងនោះមិនមែនជាអ្នកជឿក៏ដោយ ក៏ពួកគេត្រូវបានព្រះជាម្ចាស់ជ្រើសតាំងឡើងដែរ "ចូរឱ្យគ្រប់ទាំងមនុស្សចុះចូលនឹងរាជការ ត្បិតគ្មានអំណាចណាទេ លើកតែមកពីព្រះ គឺព្រះទ្រង់បានតាំងពួកលោកទាំងនោះឱ្យមានអំណាច"។ (រ៉ូម ១៣:១)

## ៧.៧. តើអ្នកត្រូវស្ដាប់តាមសិទ្ធិអំណាចណាដែលតម្រូវឱ្យអ្នកប្រព្រឹត្តអំពើបាបទាស់នឹងព្រះដែរមែនទេ?

ទេ! អ្នកមិនត្រូវស្ដាប់តាមបទបញ្ជាណា ដែលតម្រូវឱ្យអ្នកប្រព្រឹត្តអំពើបាប ទាស់នឹងព្រះជាម្ចាស់នោះឡើយ "តែពេត្រុស និងសាវ័កឯទៀតឆ្លើយឡើងថា ត្រូវតែស្ដាប់បង្គាប់ព្រះជាជាងមនុស្ស"។ (កិច្ចការ៥:២៩)

Copyright © Gratia Dei Sola Media

## ៧.៨. តើអ្នកត្រូវគោរពចំពោះមនុស្សដែលមានវ័យចាស់ជាងអ្នកនៅក្នុងពួកជំនុំយ៉ាងដូចម្ដេច?

អ្នកត្រូវគោរព និងផ្ដល់កិត្តិយសដល់ពួកគាត់ "កុំឱ្យស្ដីបន្ទោសដល់មនុស្សចាស់ៗឡើយ ចូរទូន្មានគាត់ទុកដូចជាឪពុកចុះ ហើយមនុស្សដែលក្មេងជាងអ្នក នោះទុកដូចជាប្អូនវិញ"។ (១ធីម៉ូថេ ៥:១-២)

## ៧.៩. តើវិធីដ៏សាមញ្ញមួយក្នុងការបង្ហាញការគោរព ចំពោះមនុស្សចាស់គឺជាអ្វី?

អ្នកនឹងក្រោកឡើងជម្រាបសួរពួកគាត់ ពេលគាត់ដើរមករកអ្នក"ត្រូវឱ្យឯងក្រោកឡើងឈរ នៅមុខមនុស្សចាស់សក់សត្រូវគោរពដល់មនុស្សមានវ័យចម្រើន ហើយត្រូវកោតខ្លាចដល់ព្រះនៃឯងដែរអញនេះជាព្រះយេហូវ៉ា"។ (លេវីវិន័យ១៩:៣២)

## ៧.១០. តើអ្នកត្រូវចុះចូលចំពោះមនុស្សដែលមានវ័យស្មើរនឹងអ្នកនៅក្នុងពួកជំនុំដែរឬទេ?

ពិតមែនហើយ នេះជាបំណងហឫទ័យរបស់ព្រះ ព្រះគម្ពីរចែងថា "ហើយទាំងចំណុះគ្នាទៅវិញទៅមកដោយសេចក្ដីកោតខ្លាចដល់ព្រះគ្រីស្ទ"។ (អេភេសូរ ៥:២១)។

 Copyright © Gratia Dei Sola Media

# មេរៀនទី ៨
# ការបន្ទាបខ្លួន

## ៨.១. ហេតុអ្វីបានជាអ្នកត្រូវបន្ទាបខ្លួន?

ព្រះគម្ពីរបង្រៀនយើងឱ្យបន្ទាបខ្លួន ត្បិតព្រះជាម្ចាស់ស្អប់សេចក្តីអំណួត "ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ ហើយត្រូវឱ្យគ្រប់គ្នាមានចិត្តសុភាពដល់គ្នាទៅវិញទៅមក ពីព្រោះព្រះទ្រង់តែងតតាំងនឹងមនុស្សអួតអាងតែផ្តល់ព្រះគុណដល់ពួករាបសាវិញ"។
(១ពេត្រុស ៥:៥, យ៉ាកុប ៤:៦)

## ៨.២. តើការបន្ទាបខ្លួនគឺជាអ្វី?

ការបន្ទាបខ្លួន គឺមិនមែនជាការបង្អាប់បង្ខូចខ្លួនឯងនោះទេ ប៉ុន្តែ ជាការដែលយកចិត្តទុកដាក់ ចំពោះការដែលគួរឱ្យសរសើរក្នុងជីវិតរបស់អ្នកដទៃវិញ លោកសាវ័កប៉ុលដាស់តឿនយើងថា "កុំឱ្យធ្វើអ្វីដោយទាស់ទែងគ្នា ឬដោយសេចក្តីអំណួតឥតប្រយោជន៍ឡើយ តែចូររាប់អានគ្នាឱ្យលើសជាងខ្លួនឯងដោយចិត្តសុភាពវិញ"។ (ភីលីព ២:៣)

## ៨.៣. តើអ្នកអាចរៀនបន្ទាបខ្លួនពីអ្នកណា?

រៀនពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាពិសេស"ត្រូវតែមានគំនិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើរនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ។ គឺទ្រង់បាន

Copyright © Gratia Dei Sola Media

លះបង់ព្រះអង្គទ្រង់មកយករូបភាព ជាបាវបម្រើវិញព្រម ទាំងប្រសូតមកមានរូបជាមនុស្សផង ហើយដែលទ្រង់ឃើញ មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះ ចូលស្ដាប់បង្គាប់រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់ លើឈើឆ្កាងផង”។ (ភីលីព ២:៥-៨)

## ៨.៤. តើអ្នកត្រូវបន្ទាបខ្លួនយ៉ាងដូចម្ដេច?

អ្នកត្រូវរាប់អ្នកដទៃឱ្យសំខាន់ជាងខ្លួនឯង “ខាងឯសេចក្ដី ស្រឡាញ់ជាបងប្អូន នោះចូរមានចិត្តថ្នមគ្នាទៅវិញទៅមក ចុះ ខាងឯសេចក្ដីរាប់អាននោះ ឱ្យខំរាប់អានគេជាមុន”។ (រ៉ូម១២:១០)

## ៨.៥. តើសេចក្ដីអំណួតជាអំពើបាបមែនទេ?

មែនហើយ ត្បិតព្រះជាម្ចាស់ស្អប់សេចក្ដីអំណួត “ឫកខ្ពស់ និងចិត្តអំណួត គឺចង្កៀងរបស់មនុស្សអាក្រក់ នោះហៅថាជា អំពើបាបទាំងអស់”។ (សុភាសិត ២១:៤)

## ៨.៦. លោកិយនិយាយថា “បើគ្មានអំណួត យើងគ្មានជោគជ័យទេ” ចុះព្រះគម្ពីរវិញនិយាយដូចម្ដេច?

ព្រះគម្ពីរនិយាយថា៖“ចិត្តឆ្មើងឆ្មៃរបស់មនុស្សនឹងនាំឱ្យថោក ទាបទៅ តែអ្នកណាដែលមានចិត្តសុភាពរាបទាប នោះនឹង បានកិត្តិសព្ទវិញ”។ (សុភាសិត២៩:២៣)


Copyright © Gratia Dei Sola Media

**៨.៧. តើមនុស្សដែលបន្ទាបខ្លួនអាចនឹងត្រូវសង្គមរាប់រកទេ?**

ពិតមែនហើយ វាជាព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់"ផល នៃសេចក្ដីសុភាព និងសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះគឺជាទ្រព្យសម្បត្តិ កិត្តិសព្ទ និងជីវិត" ។ (សុភាសិត២២:៤, ១៥:៣៣)

**៨.៨. នៅពេលដែលអ្នកពូកែក្នុងការងារអ្វីម្យ៉ាង តើអំណួតពីការ នោះខុសដែរឬយ៉ាងណា?**

បើសិនជាអ្នកអួតអាង មិនបានថ្វាយសិរីល្អដល់ព្រះ នោះ ទ្រង់នឹងបន្ទាបអ្នកចុះ ដើម្បីជាការល្អដល់អ្នកវិញ"អ្នកណា ដម្កើងខ្លួន អ្នកនោះនឹងត្រូវបន្ទាបចុះវិញ ហើយអ្នកណាដែល បន្ទាបខ្លួន នោះនឹងបានដម្កើងឡើង"។ (ម៉ាថាយ២៣:១២)

Copyright © Gratia Dei Sola Media

# មេរៀនទី ៩
# ភាពរាបសា

## ៩.១. តើភាពរាបសាគឺជាគុណធម៌របស់គ្រីស្ទបរិស័ទមែនទេ?

ពិតមែនហើយ វាគឺជាសញ្ញាសម្គាល់ពីភាពរាបសារបស់អ្នកជឿពិតគ្រប់គ្នា ត្បិតអ្នកនិពន្ធទំនុកដម្កើងសរសេរថា៖ "ត្បិតព្រះយេហូវ៉ា ទ្រង់សព្វព្រះហឫទ័យនឹងរាស្ត្រទ្រង់ ទ្រង់តាក់តែងមនុស្សរាបសាដោយសេចក្តីសង្គ្រោះ" (ទំនុកដម្កើង ១៤៩:៤) ព្រះយេស៊ូវមានបន្ទូលថា៖ "មានពរហើយអស់អ្នកណាដែលស្លូតត្រង់ ត្បិតអ្នកនោះនឹងគ្រងផែនដីជាមរតក"។ (ម៉ាថាយ ៥:៥)

## ៩.២. ក្រៅពីព្រះយេស៊ូវគ្រីស្ទ តើមានអ្នកណាទៀតដែលជាមនុស្សរាបសាបំផុតលើផែនដី?

លោកម៉ូសេ គឺជាមនុស្សរាបសាបំផុតនៅជំនាន់របស់គាត់ "រីឯម៉ូសេលោកសុភាពណាស់ លើសអស់ទាំងមនុស្សនៅលើផែនដី" (ជនគណនា១២:៣) ប៉ុន្តែមនុស្សដែលរាបសាបំផុតលើផែនដី គឺព្រះយេស៊ូវដែលទ្រង់មានបន្ទូលថា៖ "អស់អ្នកនឿយព្រួយហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សម្រាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ត្បិតខ្ញុំស្លូតហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសម្រាកដល់ព្រលឹង"។ (ម៉ាថាយ ១១:២៨-២៩)

 Copyright © Gratia Dei Sola Media

## ៩.៣. តើសុភាពរាបសា និងការបន្ទាបខ្លួនខុសគ្នាដូចម្ដេចខ្លះ?

សុភាពរាបសា គឺជាការបន្ទាបខ្លួន និងមានចិត្តសុភាពជាពិសេសនៅពេលដែលត្រូវអ្នកដទៃគំរាម ព្រះអម្ចាស់យេស៊ូវបានបង្ហាញភាពរាបសារបស់ទ្រង់ "កាលគេបានជេរប្រមាថដល់ទ្រង់ នោះក៏មិនបានគំហកកំហែងដល់គេដែរ គឺបានប្រគល់ព្រះអង្គទ្រង់ទៅព្រះ ដែលជំនុំជំម្រះដោយសុចរិតវិញ"។ (១ពេត្រុស ២:២៣)

## ៩.៤. ហេតុអ្វីក៏ភាពរាបសាមានសារៈសំខាន់នៅក្នុងពួកជំនុំ?

បើគ្មានភាពរាបសាទេ យើងក៏មិនមែនជាគ្រីស្ទបរិស័ទដែរ ហើយក៏គ្មានការរួបរួមក្នុងពួកជំនុំដែរ សាវ័កប៉ុលបានមានប្រសាសន៍ថា៖ "ដូច្នេះ ខ្ញុំជាអ្នកជាប់គុកក្នុងព្រះអម្ចាស់ ខ្ញុំទូន្មានអ្នករាល់គ្នាថា រឱ្យអ្នករាល់គ្នាដើរបែបគួរនឹងការងារដែលទ្រង់បានហៅមកធ្វើចុះព្រមទាំងមានចិត្តសុភាព ហើយស្លូតត្រង់គ្រប់ជំពូកទាំងអត់ធ្មត់ ហើយទ្រាំទ្រគ្នាទៅវិញទៅមកដោយស្រឡាញ់ ហើយខ្ញុំប្រឹងរក្សាសេចក្ដីរួបរួមគ្នារបស់ព្រះវិញ្ញាណ ដោយសេចក្ដីមេត្រីទុកជាចំណងផង"។
(អេភេសូរ ៤:១-៣)

## ៩.៥. តើភាពរាបសាអាចយកមកបណ្ដុះក្នុងចិត្តមនុស្សបានទេ?

ពិតជាបាន វាពិតជាមានសារសំខាន់ណាស់ក្នុងការធ្វើបែបនេះ ត្បិតហោរាសេផានាបានមានប្រសាសន៍ថា"អស់អ្នករាបសានៅផែនដី ដែលរក្សាអស់ទាំងបញ្ញាត្តច្បាប់របស់ព្រះយេហូវ៉ាអើយ ចូរស្វែងរកទ្រង់ ចូរស្វែងរកសេចក្ដីសុចរិត

Copyright © Gratia Dei Sola Media

ចូរស្វែងរកសេចក្ដីសុភាពចុះ ប្រហែលជាអ្នករាល់គ្នានឹងបាន បាំងទុកនៅក្នុងថ្ងៃនៃសេចក្ដីខ្ញាល់នៃព្រះយេហូវ៉ាទេដឹង"។ (សេផានា ២:៣)

## ៩.៦. តើខ្ញុំអាចនឹងបណ្ដុះភាពរាបសាយ៉ាងដូចម្ដេច?

ដោយចងចាំយ៉ាងខ្ជាប់ខ្ជួននូវ "សេចក្ដីសុភាព និងសេចក្ដីសម្លូតរបស់ព្រះគ្រីស្ទ" (២កូរិនថូស១០:១)"ក៏មិនគួរឱ្យបាវបម្រើនៃព្រះ អម្ចាស់ឈ្លោះគ្នាឡើយ គួរឱ្យចិត្តសុភាពរាបសាដល់មនុស្សទាំងអស់វិញ ត្រូវប្រសប់ក្នុងការបង្រៀនទាំងមានចិត្តអត់ធ្មត់ផង ត្រូវប្រដៅតម្រង់មនុស្សដែលទទឹងទទែង ដោយមានចិត្តសុភាព ក្រែងព្រះទ្រង់បណ្ដាលឱ្យគេប្រែចិត្ត ឱ្យបានស្គាល់សេចក្ដីពិតវិញ"។ (២ធីម៉ូថេ ២:២៤-២៥, ទីតុស ៣:២)

## ៩.៧. តើពួកមនុស្សដែលមានចិត្តរាបសាត្រេកអរនឹងអ្វីខ្លះនៅក្នុងជីវិតនេះ?

គឺព្រះជាម្ចាស់នឹងដឹកនាំគេ ក្នុងគ្រប់កិច្ចការដែលគេធ្វើ "ទ្រង់នឹងនាំមនុស្សសុភាពក្នុងសេចក្ដីយុត្តិធម៌ ហើយបង្រៀនមនុស្សរាបទាបឱ្យស្គាល់ផ្លូវទ្រង់"។ (ទំនុកដម្កើង ២៥:៩)


Copyright © Gratia Dei Sola Media

# មេរៀនទី ១០
# ភាពទៀងត្រង់

## ១០.១.តើអ្នកអាចរៀនអំពីភាពទៀងត្រង់ពីអ្នកណា?

រៀនពីព្រះយេស៊ូវគ្រីស្ទ "ត្បិតទ្រង់បានហៅអ្នករាល់គ្នាមកឯសេចក្តីនេះឯង ព្រោះព្រះគ្រីស្ទក៏បានរងទុក្ខជំនួសយើងដែរ ទាំងទុកតម្រាប់ឱ្យយើងដើរតាមលំអានដាននៃទ្រង់ ទ្រង់មិនដែលធ្វើបាបអ្វីសោះ ក៏មិនឃើញមានកិច្ចកលអ្វីនៅព្រះឱស្ឋទ្រង់ឡើយ"។ (១ពេត្រុស ២:២១-២២)

## ១០.២.តើភាពទៀងត្រង់នៅក្នុងពាក្យសម្តីសំខាន់ដែរមែនទេ?

ពិតហើយ ព្រះជាម្ចាស់ទ្រង់ស្អប់ពាក្យកុហក "បបូរមាត់ដែលពោលពាក្យភូតភរ ជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា តែពួកអ្នកដែលប្រព្រឹត្ត ដោយពិតត្រង់នោះ ជាទីគាប់ដល់ព្រះហឫទ័យទ្រង់វិញ"។ (សុភាសិត ១២:២២, អេភេសូរ ៤:២៥)

## ១០.៣.តើការបន្លំជាភាពមិនទៀងត្រង់មែនទេ?

ពិតមែនហើយ ការបន្លំនឹងត្រូវបានផ្តន្ទាទោសក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ "ជញ្ជីងមិនត្រឹមត្រូវ ជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា តែកូនជញ្ជីងគ្រប់ទម្ងន់ ជាទីគាប់ដល់ព្រះទ័ហឫទ័យទ្រង់វិញ"។ (សុភាសិត ១១:១)

Copyright © Gratia Dei Sola Media

**១០.៤.តើការធ្វើពុតជាខំប្រឹងធ្វើការពេលដែលលោកគ្រូអ្នកគ្រូឬឪពុកម្ដាយកំពុងឃ្លាំមើលជាការត្រឹមត្រូវដែរឬទេ?**

ទេ! ខ្ញុំមិនត្រូវធ្វើពុតដាច់ខាត អ្នកត្រូវកោតខ្លាចព្រះជាម្ចាស់ "ពួកបាវបម្រើអើយ ចូរស្ដាប់បង្គាប់ចៅហ្វាយនាយខាងសាច់ឈាមក្នុងគ្រប់ការទាំងអស់ចុះ មិនមែនតែកាលនៅមុខគេប៉ុណ្ណោះ ដូចជាចង់ផ្គាប់ចិត្តមនុស្សនោះទេ គឺដោយចិត្តស្មោះត្រង់វិញ ទាំងកោតខ្លាចដល់ព្រះផង"។

(កូល៉ុស ៣:២២)

**១០.៥.តើការនិយាយបញ្ឆោរ ឬបំផ្លើសជាការត្រឹមត្រូវដែរឬទេ?**

ទេ! ព្រះជាម្ចាស់ស្អប់អណ្ដាតណាដែលបញ្ចោរ "ព្រះយេហូវ៉ាទ្រង់នឹងកាត់អស់ទាំងបបូរមាត់បញ្ចើច ព្រមទាំងអណ្ដាតដែលពោលពាក្យធំនោះផង"។

(ទំនុកដម្កើង១២:៣)

**១០.៦.តើយើងត្រូវកែរតម្រង់កំហុសឆ្គង ឬពាក្យកុហកពីអតីតកាលដែរឬទេ?**

ពិតមែនហើយ បើសិនជាអ្នកធ្លាប់និយាយកុហក អ្នកត្រូវតែកែប្រែដោយសេចក្ដីពិតវិញ "ហេតុនោះបានខ្ញុំប្របាទខំប្រឹងឱ្យមានបញ្ញាចិត្តឥតសៅហ្មងនៅចំពោះព្រះ និងចំពោះមនុស្សលោកជានិច្ចដែរ"។

(កិច្ចការ ២៤:១៦, ២កូរិនថូស ៨:២១)

 Copyright © Gratia Dei Sola Media

**១០.៧.តើភាពទៀងត្រង់ជាគោលការណ៍ល្អបំផុតសម្រាប់ជីវិតរស់នៅមែនទេ?**

ប្រាកដណាស់ត្បិត "សេចក្ដីសុចរិតរបស់មនុស្សទៀងត្រង់នឹងនាំផ្លូវគេ តែសេចក្ដីវៀចវេររបស់មនុស្សប្រទូស្តនឹងនាំឱ្យវិនាសវិញ"។ (សុភាសិត១១:៣, ១៩:១)

**១០.៨.តើការសូកប៉ាន់ ដើម្បីនឹងសម្រេចកិច្ចការអ្វីមួយជាការខុសដែរឬយ៉ាងណា?**

មែនហើយ លោកិយតែងតែសូកប៉ាន់ ប៉ុន្តែគ្រីស្ទបរិស័ទតែប្រឆាំងនឹងទង្វើរមិនទៀងត្រង់បែបនេះ ត្បិតលោកម៉ូសេបានមានប្រសាសន៍ថា "មិនត្រូវបង្វែរសេចក្ដីយុត្តិធម៌ឡើយ ក៏មិនត្រូវលម្អៀងចិត្តទៅខាងណា ឬស៊ីសំណូកឡើយ ត្បិតសំណូកជាការនាំឱ្យបំបិទភ្នែកអ្នកប្រាជ្ញ ហើយក៏បង្ខូចពាក្យសម្ដីរបស់មនុស្សសុចរិតផង"។ (ចោទិយកថា១៦:១៩)

Copyright © Gratia Dei Sola Media

# មេរៀនទី ១១
# ការលះបង់ខ្លួនឯង និង ការគិតអំពីអ្នកដទៃ

## ១១.១.តើការលះបង់ខ្លួនឯងត្រូវបានបង្គាប់ក្នុងព្រះគម្ពីរមែនទេ?

ពិតប្រាកដណាស់ "កុំឱ្យគ្រប់គ្នាស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ ត្រូវស្វែងរកចំពោះអ្នកដទៃផង"។ (ភីលីព ២:៤, ១កូរិនថូស ១០:២៤)

## ១១.២.តើអ្នកណាដែលបានធ្វើជាឧទាហរណ៍អស្ចារ្យបំផុតអំពីការលះបង់ខ្លួនឯង?

ព្រះអម្ចាស់យេស៊ូវគ្រីស្ទ "ត្បិតអ្នករាល់គ្នាបានស្គាល់ ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ហើយថាទោះបើទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ ដោយព្រោះអ្នករាល់គ្នា ដើម្បីឱ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្តីកម្ររបស់ទ្រង់"។ (២កូរិនថូស៨:៩)

## ១១.៣.តើមានអ្វីខ្លះដែលត្រូវគិត?

គិតអំពីអ្នកដទៃព្រមទាំងព្យាយាមជួយគេ ប្រកបដោយចិត្តសប្បុរសផង "គួរតែឱ្យយើងរាល់គ្នា ដែលមានកម្លាំង បានទ្រាំទ្រនឹងភាពកម្សោយរបស់ពួកអ្នក ដែលគ្មានកម្លាំងវិញ ឥតបំពេញចិត្តខ្លួនយើងឡើយ ត្រូវឱ្យយើងរាល់គ្នាបំពេញចិត្តអ្នកជិតខាងខ្លួន សម្រាប់ជាសេចក្តីល្អឱ្យបានស្អាងចិត្ត


Copyright © Gratia Dei Sola Media

ឡើង ត្បិតព្រះគ្រីស្ទទ្រង់មិនបានបំពេញព្រះហឫទ័យទ្រង់ដែរ"។ (រ៉ូម ១៥:១-៣)

**១១.៤.តើការគិតអំពីអ្នកដទៃមានន័យថា មិនបង្ករឿងឱ្យអ្នកផ្សេងមែនទេ?**

ទេ! ការគិតអំពីអ្នកដទៃ ជួនកាលក៏តម្រូវឱ្យយើងកែកំហុសរបស់អ្នកដទៃដែរ "ហើយត្រូវឱ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីបណ្ដាលឱ្យមានសេចក្តីស្រឡាញ់ ហើយឱ្យប្រព្រឹត្តការល្អផង"។
(ហេព្រើរ ១០:២៤, រ៉ូម១៤:១៩)

**១១.៥.តើចិត្តសុភាព គឺជាគុណធម៌របស់គ្រីស្ទបរិស័ទមែនទេ?**

មែនហើយ ចិត្តសុភាពរាបសា គឺជាចំណែកមួយនៃការគិតអំពីអ្នកដទៃ "ក្រោយបង្អស់នេះ ចូរឱ្យគ្រប់គ្នាមានគំនិតតែមួយ ព្រមទាំងមានចិត្តអាណិតអាសូរ ហើយស្រឡាញ់គ្នាជាបងប្អូន និងមានចិត្តទន់សណ្ដោសហើយសុភាព"។
(១ពេត្រុស ៣:៨)

**១១.៦.តើយើងត្រូវជួយគ្នាទៅវិញទៅមកមែនទេ?**

ពិតមែនហើយ ត្បិតព្រះគ្រីស្ទជាព្រះអម្ចាស់នៃយើងបង្រៀនយើងថា យើងត្រូវតែបម្រើគ្នាទៅវិញទៅមក "ដូច្នេះបើខ្ញុំដែលជាព្រះអម្ចាស់ ហើយជាគ្រូបានលាងជើងឱ្យអ្នករាល់គ្នា នោះគួរតែឱ្យអ្នករាល់គ្នាលាងជើងដល់គ្នានឹងគ្នាដែរ"។ (យ៉ូហាន ១៣:១៤)

Copyright © Gratia Dei Sola Media

**១១.៧.តើការជួយគ្នាទៅវិញទៅមកមានន័យយ៉ាងណា?**

វាមានន័យថា ជួយយកអាសារគ្នាទៅវិញទៅមក-"ចូរយកអាសារគ្នាទៅវិញទៅមក យ៉ាងនោះទើបបានសម្រេចតាមក្រិត្យវិន័យនៃព្រះគ្រីស្ទ"។ (កាឡាទី៦:២)

**១១.៨.ចូរលើកឧទាហរណ៍ខ្លះៗដែលនិយាយអំពីការជួយយកអាសារគ្នានិងការគិតអំពីអ្នកដទៃ ។**

ការធ្វើទានដល់មនុស្សទាល់ក្រ និងការបង្ហាញនូវការទទួលរាក់ទាក់ "ខាងសេចក្តីខ្វះខាតរបស់ពួកបរិសុទ្ធ នោះចូរផ្គត់ផ្គង់ឱ្យទាំងខំប្រឹងឱ្យមានសេចក្តីចៅរៅផងចុះ"។ (រ៉ូម ១២:១៣)

**១១.៩.តើអ្នកត្រូវជួយយកអាសារដល់មនុស្សដែលមិនប្រាកដថានឹងចេះដឹងគុណដែរមែនទេ?**

មែនហើយ ត្បិតព្រះអម្ចាស់បង្រៀនយើងថា "ដែលឱ្យនោះបានពរជាជាងទទួល"។ (កិច្ចការ ២០:៣៥)

 Copyright © Gratia Dei Sola Media

# មេរៀនទី ១២
# ការស្កប់ចិត្ត

**១២.១.តើការស្កប់ចិត្តត្រូវបានបង្គាប់ក្នុងព្រះគម្ពីរដែរមែនទេ?**

ពិតណាស់ វាជាបញ្ញាត្តិទី១០នៃក្រិត្យវិន័យ "កុំឱ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួនឱ្យសោះ ក៏កុំឱ្យលោភចង់បានប្រពន្ធគេ ឬបាវប្រុសស្រីគេក្តី ឬគោ លា ឬរបស់អ្វីផងអ្នកជិតខាងខ្លួនឱ្យសោះ"។ (និក្ខមនំ២០:១៧)

**១២.២.តើការស្កប់ចិត្តជាគុណធម៌ដ៏សំខាន់របស់គ្រីស្ទបរិស័ទទេ?**

ពិតមែនហើយត្បិត "ការគោរពប្រតិបត្តិដល់ព្រះ ដែលមានទាំងចិត្តស្កប់ស្កល់ផងនោះជាកម្រៃមួយយ៉ាងធំមែន"។ (១ធីម៉ូថេ ៦:៦, ៦:៧-១០)

**១២.៣.តើអ្នកអាចស្កប់ចិត្តដែរឬទេ បើសិនអ្នកជាអ្នកក្រ?**

គឺពិតប្រាកដណាស់ "ខ្ញុំបានរៀនឱ្យមានសេចក្តីសណ្តោសក្នុងសណ្ឋានគ្រប់យ៉ាង ដែលខ្ញុំធ្លាប់ទ្រាំឱ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះ ក្នុងសារពើទាំងអស់ហើយ"។ (ភីលីព ៤:១១-១២)

**១២.៤.តើយើងអាចរៀនពីការស្កប់ចិត្តក្នុងភាពក្រីក្រពីអ្នកណាជាពិសេស?**

ពីព្រះអម្ចាស់យេស៊ូវគ្រីស្ទជាព្រះរាជបុត្រា នៃព្រះដែលទ្រង់មានបន្ទូលថា៖ "កញ្ជ្រោងមានរូងវា ហើយសត្វហើរលើ

អាកាសក៏មានសម្បុកដែរ តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ"។ (ម៉ាថាយ ៨:២០)

## ១២.៥.តើការដែលក្រនោះតែងល្អជាងមានជានិច្ចមែនទេ?

វាមិនមែនដូច្នោះនោះទេ តែក៏មិនចាំបាច់ដែរព្រះបាទអេគើរអធិស្ឋានថា "សូមកម្ចាត់សេចក្ដីភូតភរ និងពាក្យកុហកឱ្យឆ្ងាយពីទូលបង្គំទៅ ហើយសូមកុំឱ្យទូលបង្គំមានសេចក្ដីទ័លក្រ ឬជាអ្នកមានដែរ សូមគ្រាន់តែចិញ្ចឹមជីវិតទូលបង្គំដោយអាហារដែលត្រូវការប៉ុណ្ណោះ ក្រែងទូលបង្គំបានឆ្អែតហើយបោះបង់ចោលទ្រង់ដោយពាក្យថា ព្រះយេហូវ៉ាជាអ្នកណាហ្ន៎ ឬក្រែងទូលបង្គំមានសេចក្ដីទ័លក្រទៅជាលួចគេ ព្រមទាំងប្រើព្រះនាមនៃព្រះ ជាទីមើលងាយផង"។ (សុភាសិត ៣០:៨-៩)

## ១២.៦.តើការស្កប់ចិត្តពាក់ព័ន្ធនឹងរឿងមាននិងក្រតែប៉ុណ្ណោះឬ?

ទេ! វាក៏ពាក់ព័ន្ធនឹងស្ថានការណ៍រស់នៅ និងកេរ្តិ៍ឈ្មោះ យើងដែរ លោកសាវ័កប៉ុលមានប្រសាសន៍ថា "បងប្អូន អើយ អ្នករាល់គ្នាមានសណ្ឋានយ៉ាងណា ក្នុងកាលដែល ព្រះទ្រង់ហៅមកនោះឱ្យប្រព្រឹត្តតាម សណ្ឋាននោះនៅ ចំពោះទ្រង់ចុះ" (១កូរិនថូស ៧:២៤) ហើយ "កុំឱ្យយើង រាល់គ្នារកកេរ្តិ៍ឈ្មោះដែលឥតប្រយោជន៍ទាំងចាក់រុក ហើយឈ្នានីសគ្នាទៅវិញទៅមកឡើយ"។ (កាឡាទី ៥:២៦)

 Copyright © Gratia Dei Sola Media

**១២.៧.តើយើងត្រូវបានជម្រុញឱ្យស្កប់ចិត្តយ៉ាងដូចម្ដេច?**

គឺតាមរយៈការនឹកចាំពីសេចក្ដីសន្យារបស់ព្រះអម្ចាស់ ដែលនៅជាប់ជាមួយនឹងយើជានិច្ច "ចូរឱ្យកិរិយាដែលអ្នករាល់គ្នាប្រព្រឹត្តបានឥតលោភឡើយ ឱ្យស្កប់ចិត្តនឹងរបស់ដែលមានហើយប៉ុណ្ណោះចុះ ត្បិតព្រះទ្រង់មានបន្ទូលថា "អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ"។ (ហេព្រើរ១៣:៥)

# មេរៀនទី ១៣
# ភាពកត្តញ្ញូ ឬ ការដឹងគុណ

## ១៣.១.តើការដឹងគុណត្រូវបានបង្គាប់ក្នុងព្រះគម្ពីរដែរមែនទេ?

មែនហើយ ការនេះត្រូវបានបង្គាប់ជាច្រើនកន្លែងក្នុងព្រះគម្ពីរ។ ឧទាហរណ៍ លោកសាវ័កប៉ុលមានប្រសាសន៍ថា "ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ ត្បិតព្រះទ្រង់សព្វព្រះហឫទ័យឱ្យអ្នករាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវព្រះគ្រីស្ទយេស៊ូវ"។ (១ថែស្សាឡូនីច ៥:១៨)

## ១៣.២.តើភាពកត្តញ្ញូសំខាន់ណាស់មែនទេ?

មែនហើយ នៅពេលដែលព្រះអម្ចាស់បានប្រោសមនុស្សឃ្លង់ដប់នាក់ឱ្យបានជានោះ មានតែម្នាក់ប៉ុណ្ណោះដែលបានត្រឡប់មកអរព្រះគុណទ្រង់។ ព្រះអង្គសព្វព្រះហឫទ័យនឹងគាត់ណាស់ ទ្រង់មិនសព្វព្រះទ័យនឹងអ្នកឯទៀតឡើយព្រះអង្គមានបន្ទូលថា "តើអ្នកទាំងដប់នោះមិនបានជាស្អាតទេឬអី? ចុះប្រាំបួននាក់ទៀតនៅឯណា? តើឃើញមានតែសាសន៍ដទៃមួយនេះទេឬ ដែលវិលមកសរសើរដម្កើងដល់ព្រះ?" រួចទ្រង់មានបន្ទូលទៅអ្នកនោះថា "ចូរក្រោកឡើងទៅចុះសេចក្ដីជំនឿអ្នកបានសង្គ្រោះអ្នកហើយ"។
(លូកា១៧:១៧-១៨)

 Copyright © Gratia Dei Sola Media

## ១៣.៣.តើយើងត្រូវបង្ហាញភាពកត្តញ្ញូដល់ព្រះជាម្ចាស់ដោយរបៀបណា?

ដោយអរគុណក្នុងព្រះនាម ព្រះអម្ចាស់យេស៊ូវគ្រីស្ទ "ដូច្នេះត្រូវឱ្យយើងថ្វាយពាក្យសរសើរដោយសារទ្រង់ ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់"។ (ហេព្រើរ១៣:១៥,រ៉ូម១:៨,កូល៉ុស ៣:១៧, ទំនុកដម្កើង ១០០:៤)

## ១៣.៤.តើយើងត្រូវអរព្រះគុណព្រះជាម្ចាស់ចំពោះចំណងមិត្តភាពជាមួយបងប្អូនរួមជំនឿដែរមែនទេ?

ពិតប្រាកដណាស់ យើងត្រូវធ្វើដូចលោកសាវ័កប៉ុល ដែលមានប្រសាសន៍ទៅកាន់ពួកជំនុំ នៅក្រុងភីលីពថា "ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ ដោយព្រោះគ្រប់ទាំងសេចក្ដីដែលខ្ញុំនឹកចាំពីអ្នករាល់គ្នា"។ (ភីលីព ១:៣)

## ១៣.៥.តើការអរព្រះគុណមុនពេលបរិភោគអាហារជាការសំខាន់សម្រាប់យើងដែរទេ?

មែនហើយ ព្រះយេស៊ូវគ្រីស្ទតែងអរព្រះគុណមុនពេលទ្រង់សោយអាហារ ឧទាហរណ៍ថា មុនពេលដែលទ្រង់ប្រទានអាហារដល់មនុស្សបួនពាន់នាក់ "នោះទ្រង់បង្គាប់ឱ្យហ្វូងមនុស្សអង្គុយនៅដី រួចយកនំបុ័ងទាំងប្រាំពីរនោះមកអរព្រះគុណ ហើយកាច់ប្រទានដល់ពួកសិស្ស ឱ្យលើកទៅជូនដល់ហ្វូងមនុស្ស គេក៏លើកទៅ"។ (ម៉ាកុស ៨:៦)

Copyright © Gratia Dei Sola Media

## ១៣.៦.តើការអរព្រះគុណដោយសម្លេងរបស់យើង គឺជាវិធីតែមួយគត់ក្នុងការបង្ហាញនូវភាពកត្តញ្ញូរបស់យើងចំពោះព្រះជាម្ចាស់មែនទេ?

ទេ! មិនមែនទេ យើងត្រូវតែរស់នៅក្នុងជីវិតគ្រីស្ទបរិស័ទដោយភាពកត្តញ្ញូ លោកសាវ័កប៉ុលបានមានប្រសាសន៍ថា "ដូច្នេះដែលអ្នករាល់គ្នាបានទទួលព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់បែបយ៉ាងណា នោះចូរដើរក្នុងទ្រង់បែបយ៉ាងនោះចុះ ដោយបានចាក់ឫស ហើយស្អាងឡើងក្នុងទ្រង់ ទាំងតាំងនៅខ្ជាប់ខ្ជួនក្នុងសេចក្តីជំនឿ ដូចជាបានបង្រៀនដល់អ្នករាល់គ្នាហើយ ព្រមទាំងអរព្រះគុណកាន់តែច្រើនឡើងទៀតផង" (កូល៉ុស២:៦-៧) ហើយថា "ដោយសារសេចក្តីនេះឯង យើងរាល់គ្នាបានស្គាល់សេចក្តីស្រឡាញ់។ គឺទ្រង់បានស៊ូប្តូរព្រះជន្មទ្រង់ជំនួសយើង ដូច្នេះគួរឱ្យយើងប្តូរជីវិតយើងជំនួសបងប្អូនដែរ"។ (១យ៉ូហាន៣:១៦)

## ១៣.៧.តើយើងត្រូវបង្ហាញភាពកត្តញ្ញូចំពោះមនុស្សដែលប្រព្រឹត្តល្អដល់យើងដែរមែនទេ?

មែនហើយ គឺយើងត្រូវតែដើរតាមឧទាហរណ៍ របស់មនុស្សដែលគោរពកោតខ្លាចព្រះនៅក្នុងព្រះគម្ពីរ ដូចជាព្រះបាទដាវីឌ ដែលបានមានបន្ទូលប្រាប់ដល់ព្រះបាទសាឡូម៉ូនថា "ចូរសម្តែងសេចក្តីសប្បុរសដល់ពួកកូនបារស៊ីឡាយ ជាពួកស្រុកកាឡាតវិញ ហើយឱ្យគេនៅក្នុងពួកអ្នកដែលបរិភោគ


Copyright © Gratia Dei Sola Media

នៅតុងង ត្បិតគេបានមកទទួលអញ នៅគ្រាដែលអញបាន
រត់ពីអាប់សាឡុំមជាបងឯងទៅ”។ (១ពង្សាវតារក្សត្រ២:៧)

Copyright © Gratia Dei Sola Media

# មេរៀនទី ១៤
# ការអត់ទោស

## ១៤.១. ហេតុអ្វីក៏យើងត្រូវអត់ទោសឱ្យគ្នាទៅវិញទៅមក?

ព្រោះព្រះបានអត់ទោសបាបឱ្យយើង ត្បិតដូចដែលសាវ័កប៉ុលបានបង្គាប់មកថា "ចូរមានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមកព្រមទាំងមានចិត្តទន់សណ្ដោស ហើយអត់ទោសគ្នាដូចជា ព្រះទ្រង់បានអត់ទោសឱ្យអ្នករាល់គ្នា ដោយព្រះគ្រីស្ទដែរ" (អេភេសូរ ៤:៣២)។

## ១៤.២.តើអ្នកត្រូវអត់ទោសឱ្យអ្នកណាខ្លះ?

ឱ្យគ្រប់គ្នាដែលមករកខ្ញុំ ចូរសារភាពកំហុសដែលគេបានប្រព្រឹត្តលើអ្នក ត្បិតព្រះអម្ចាស់យេស៊ូវ ទ្រង់មានបន្ទូលថា "ចូរប្រយ័ត្នខ្លួន បើបងប្អូនធ្វើបាបនឹងអ្នក ត្រូវឱ្យអ្នកបន្ទោសដល់គាត់ បើគាត់ប្រែចិត្តមកវិញ នោះចូរអត់ទោសដល់គាត់ចុះ"។ (លូកា ១៧:៣)

## ១៤.៣.តើអ្នកត្រូវអត់ទោសដល់បងប្អូនដែលធ្វើបាបលើអ្នកចំនួនប៉ុន្មានដង?

បើគាត់មកសុំទោសប៉ុន្មានដងនោះ ចូរអត់ទោសដល់គាត់ប៉ុណ្ណឹងដែរទៅចុះ នៅពេលដែលលោកសាវ័កពេត្រុសទូលសួរថា "ព្រះអម្ចាស់អើយ បើបងប្អូនធ្វើបាបនឹងខ្ញុំ នោះត្រូវឱ្យខ្ញុំអត់ទោសឱ្យគេប៉ុន្មានដង? តើដល់ប្រាំពីរដងឬអី?" (ម៉ាថាយ១៨:២១) ព្រះយេស៊ូវទ្រង់មានបន្ទូលតបថា "ខ្ញុំមិន


Copyright © Gratia Dei Sola Media

ថាឱ្យអ្នកអត់ទោសប្រាំពីរដងទេ គឺដល់ប្រាំពីរចិតសិបដង ទៅទៀត" (ម៉ាថាយ ១៨:២២)។

## ១៩.៤.ចុះបើបងប្អូនរបស់អ្នកនៅតែធ្វើបាបដដែលមកលើអ្នក?

ខ្ញុំនៅតែត្រូវអត់ទោសគេ ត្បិតព្រះអម្ចាស់មានបន្ទូលថា "បើគាត់ធ្វើបាបនឹងអ្នកប្រាំពីរដងក្នុងមួយថ្ងៃ ហើយត្រឡប់មកនិយាយនឹងអ្នកប្រាំពីរដងថា អ្នកប្រែចិត្តហើយ នោះត្រូវឱ្យអ្នកអត់ទោសឱ្យគាត់ជាកុំខាន"។ (លូកា ១៧:៤)

## ១៩.៥.ចុះបើអ្នកមិនព្រមអត់ទោសឱ្យអ្នកណាម្នាក់តើយ៉ាងម៉េចទៅវិញ?

បើខ្ញុំមានះមិនព្រមអត់ទោសបាប នោះអ្នកមិនអាចធ្វើជាកូនរបស់ព្រះបានឡើយ ត្បិតព្រះអម្ចាស់បានមានបន្ទូលថា "ត្បិតបើអ្នករាល់គ្នាអត់ទោសចំពោះ ការរំលងច្បាប់ដែលមនុស្សលោកប្រព្រឹត្តធ្វើនោះ ព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងអត់ទោសឱ្យអ្នករាល់គ្នាដែរ តែបើអ្នករាល់គ្នាមិនអត់ទោសចំពោះការរំលងច្បាប់ឱ្យគេទេ នោះព្រះវរបិតានៃអ្នក ទ្រង់ក៏មិនអត់ទោសចំពោះការរំលងច្បាប់ដែលអ្នករាល់គ្នាប្រព្រឹត្តធ្វើដែរ"។
(ម៉ាថាយ៦:១៤-១៥, ម៉ាកុស ១១:២៥-២៦)

## ១៩.៦.ចុះបើអ្នកដែលធ្វើខុសនោះគាត់មិនបានមកសុំទោសអ្នក តើយ៉ាងណាវិញ?

អ្នកក៏នៅតែមិនត្រូវប្រកាន់ទោសគាត់ ហើយក៏មិនត្រូវគិតសងសឹកដែរ ត្បិតព្រះអម្ចាស់មានបន្ទូលថា "ការសងសឹកនោះស្រេចនឹងអញ" (រ៉ូម ១២:១៩) ហើយលោកយ៉ាកុបមានប្រសាសន៍ថា "បងប្អូនអើយ កុំឱ្យរទូរទាំទាស់នឹងគ្នាទៅវិញទៅមកឡើយ ក្រែងមានទោស មើលចៅក្រមលោកឈរនៅមាត់ទ្វារហើយ"។ (យ៉ាកុប៥:៩)


Copyright © Gratia Dei Sola Media

# មេរៀនទី ១៥
# កំហឹង

## ១៥.១.តើកំហឹងជាអំពើបាបរហូតមែនទេ?

មិនមែនទេ ពីព្រោះព្រះអម្ចាស់ក៏ខ្ញាល់ដែរ ប៉ុន្តែទ្រង់មិនបានប្រព្រឹត្តអំពើបាប (ម៉ាកុស ៣:៥, ហេព្រើរ ៣:១៥) ហើយលោកសាវ័កប៉ុល ក៏មានប្រសាសន៍ដែរថា៖ "ចូរខឹងចុះតែកុំឱ្យធ្វើបាបឡើយ"។ (អេភេសូរ ៤:២៦ក)

## ១៥.២.តើកំហឹងក្លាយជាអំពើបាបនៅពេលណា?

នៅពេលដែលកំហឹងនោះអាត្មានិយម គ្មានហេតុផល ឬហួសហេតុពេក ព្រះអម្ចាស់មានបន្ទូលថា៖ "អ្នករាល់គ្នាបានឮសេចក្ដីដែលសម្ដែងដល់មនុស្សពីបុរាណថា កុំឱ្យសម្លាប់មនុស្សឱ្យសោះ បើអ្នកណាសម្លាប់មនុស្ស នោះក្រែងត្រូវជាប់ជំនុំជម្រះហើយ តែខ្ញុំប្រាប់អ្នករាល់គ្នា ដូច្នេះវិញថា សូម្បីតែអ្នកណាដែលខឹងនឹងបងប្អូន នោះក្រែងត្រូវជាប់ជំនុំជម្រះដែរ"។ (ម៉ាថាយ ៥:២១-២២)

## ១៥.៣.តើវាត្រឹមត្រូវដែរឬទេ ដែលត្រូវទុកកំហឹងរាប់សិបថ្ងៃដោយព្រោះតែហេតុផលរបស់យើងនោះ?

ទេ! មិនត្រូវទេ ត្បិតមេកំណាចនឹងប្រើអ្នកជាប្រយោជន៍នៃខ្លួនវាមិនខាន លោកសាវ័កប៉ុលបានមានប្រសាសន៍ថា៖ "កុំឱ្យសេចក្ដី កំហឹងរបស់អ្នកនៅដរាបដល់ថ្ងៃលិចឡើយ ក៏កុំឱ្យអារក្សមានឱកាសឱ្យសោះ"។ (អេភេសូរ៤:២៦ខ-២៧)

**១៥.៤.តើអ្នកត្រូវធ្វើដូចម្តេច បើមានអ្នកធ្វើឱ្យអ្នកក្តៅក្រហាយ?**

អ្នកត្រូវរៀនទប់អារម្មណ៍ខ្លួនឯង ព្រះបាទសាឡូម៉ូនមានបន្ទូលថាៈ "អ្នកណាដែលយឺតនឹងខឹង នោះមានកម្លាំងខ្លាំង ហើយអ្នកណាដែលឈ្នះចិត្តខ្លួន ក៏វិសេសជាងអ្នកដែលឈ្នះយកបានទីក្រុងទៅទៀត"។ (សុភាសិត១៦:៣២)

**១៥.៥.ចុះបើសិនជាគេនិយាយអ្វីបញ្ឈឺអ្នកនោះយ៉ាងម៉េចទៅវិញ?**

អ្នកត្រូវព្យាយាមធ្វើយ៉ាងណាកុំខឹង ហើយព្យាយាមបំភ្លេចសម្តីគាត់ បើសិនជាអាចត្បិត "សតិបញ្ញារបស់មនុស្សនឹងនាំឱ្យយឺតនឹងខឹង អ្នកនោះក៏តែងមានចិត្តអរ ដោយមិនប្រកាន់ទោសវិញ"។ (១ពេត្រុស ៣:៨)

**១៥.៦.តើអ្នកអាចធ្វើអ្វីខ្លះដើម្បីទប់កំហឹងមិនឈ្លោះជាមួយនឹងមិត្តរបស់អ្នក?**

មិនត្រូវយកសម្តីកំហឹងទៅទល់នឹងកំហាល់ឡើយ "ត្បិតពួកល្ងីល្ងើសម្តែងចេញអស់ទាំងកំហឹងរបស់ខ្លួន តែមនុស្សមានប្រាជ្ញាគេទប់ចិត្តហើយរម្ងាប់ចេញវិញ"។
(សុភាសិត២៩:១១)

**១៥.៧.បើសិនជាអ្នកកំពុងឈ្លោះជាមួយនឹងនរណាម្នាក់តើអ្នកអាចធ្វើអ្វីខ្លះដើម្បីបញ្ឈប់ជម្លោះនេះ?**

ត្រូវនិយាយសម្តីទន់ភ្លន់ ដោយថ្នមសម្លេង "ត្បិតពាក្យតបឆ្លើយដោយស្រទន់ នោះរមែងរម្ងាប់សេចក្តីក្រោធទៅ តែពាក្យគំរោះគំរើយនោះបណ្តាលឱ្យមានសេចក្តីកំហឹង"។

 Copyright © Gratia Dei Sola Media

(សុភាសិត ១៥:១)

**១៥.៨.តើវាសំខាន់ដែរទេដែលអ្នកត្រូវប្រញាប់ដោះស្រាយការទាស់សម្ដីដែលអ្នកមានជាមួយនឹងមិត្តភ័ក្រ្ត?**

ពិតណាស់ បើសិនជាអាចធ្វើទៅបាន អ្នកមិនត្រូវបណ្ដោយឱ្យបញ្ហានេះ រីកធំហួសពីការដែលអាចគ្រប់គ្រងបាននោះឡើយត្បិតព្រះបាទសាឡូម៉ូនមានបន្ទូលថា "ការចាប់ផ្ដើមប្រកាន់គ្នានោះ ប្រៀបដូចជាបើកទំនប់ទឹក ដូច្នេះចូរលើកការទាស់គ្នាចេញ មុនដែលកើតមានការប្រឈ្លោះគ្នាផង"។ (សុភាសិត ១៧:១៤)

**១៥.៩.បើសិនជាមានគេខឹងនឹងអ្នកតើអ្នកត្រូវធ្វើដូចម្ដេច?**

អ្នកត្រូវព្យាយាមផ្សះផ្សាជាមួយនឹងគាត់ (ម៉ាថាយ ៥:២៣-២៤, ១៨:១៥)ហើយការផ្ដល់ជាកាដូ (អំណោយ) ប្រហែលជាអាចជួយបានត្បិត "អំណោយដែលឱ្យដោយស្ងាត់កំបាំងនោះរមែងរម្ងាប់សេចក្ដីកំហឹង ហើយជំនូនដែលជូនដោយលួចលាក់ក៏បំបាត់សេចក្ដីឃោរឃៅដែរ"។

(សុភាសិត ២១:១៤)

Copyright © Gratia Dei Sola Media

# មេរៀនទី ១៦
# ភាពស្មោះត្រង់ និង ទំនួលខុសត្រូវ

**១៦.១.តើភាពស្មោះត្រង់ដូចគ្នានឹងសេចក្តីជំនឿមែនដែរទេ?**

មិនមែនទេ សេចក្តីជំនឿជាការជឿ រីឯភាពស្មោះត្រង់ គឺជាការប្រកាន់ការពិតចំពោះការសន្យា និងភារកិច្ចរបស់យើង គេនិយាយថា ព្រះជាម្ចាស់ទ្រង់ស្មោះត្រង់ ពីព្រោះទ្រង់រក្សាព្រះបន្ទូលសន្យារបស់ទ្រង់ ដូច្នេះបានជាអ្នកសរសេរទំនុកដម្កើង គេសរសេរថា៖ "ទូលបង្គំនឹងច្រៀងពីព្រះគុណនៃព្រះយេហូវ៉ាជាដរាប មាត់ទូលបង្គំនឹងសម្តែងឱ្យស្គាល់សម្តីស្មោះត្រង់របស់ទ្រង់ រហូតដល់អស់ទាំងតំណតទៅ"។ (ទំនុកដម្កើង៨៩:១)

**១៦.២.តើយើងអាចរៀនអំពីភាពស្មោះត្រង់ និងទំនួលខុសត្រូវនេះពីអ្នកណាមក?**

គឺរៀនពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលស្មោះត្រង់នឹងព្រះវរបិតាទ្រង់ "គឺដែលទ្រង់ស្មោះត្រង់ដល់ព្រះដែលតាំងទ្រង់ ដូចជាលោកម៉ូសេស្មោះត្រង់ ក្នុងដំណាក់នៃព្រះទាំងមូលដែរ"។ (ហេព្រើរ៣:២)

 Copyright © Gratia Dei Sola Media

## ១៦.៣.តើធ្វើជាអ្នកបម្រើស្មោះត្រង់ចំពោះព្រះអម្ចាស់ត្រូវធ្វើដូចម្ដេច?

គឺធ្វើឱ្យជីវិតអ្នកមានប្រយោជន៍សម្រាប់ព្រះអម្ចាស់ ដោយប្រើអស់ទាំងទេពកោសល្យ ដែលទ្រង់បានប្រទានឱ្យអ្នក ត្បិតចៅហ្វាយ នៅក្នុងរឿងប្រៀបប្រដូច របស់ព្រះអម្ចាស់និយាយអំពីបុរសម្ចាស់ទ្រព្យ ដែលពោលទៅកាន់បាវបម្រើរបស់ខ្លួនថា៖ "ប្រពៃហើយ បាវល្អស្មោះត្រង់អើយ! ឯងមានចិត្តស្មោះនឹងត្រួតរបស់បន្តិចបន្តួចនេះ ដូច្នេះអញនឹងតាំងឯងត្រួតលើរបស់ជាច្រើនទៅទៀត ចូរឱ្យឯងប្រកបដោយសេចក្ដីអំណររបស់ចៅហ្វាយឯងចុះ"។

(ម៉ាថាយ២៥:២១, ២៣)

## ១៦.៤.តើការស្មោះត្រង់ក្នុងពាក្យសម្ដីអ្នកមានន័យយ៉ាងណា?

គឺនិយាយនូវសេចក្ដីពិត៖ "សាក្សីស្មោះត្រង់នឹងមិនកុហកឡើយ តែសាក្សីក្លែងក្លាយតែងតែពោលពាក្យភូតភរវិញ"។

(សុភាសិត ១៤:៥)

## ១៦.៥.តើការស្មោះត្រង់ចំពោះបងប្អូនរួមជំនឿមានន័យដូចម្ដេច?

គឺត្រូវជួយយកអាសារពួកគេជាពិសេស ត្បិតលោកសាវ័កយ៉ូហានបានទូន្មានលោកកៃយុសថា៖ "អ្នកស្ងួនភ្ងាអើយការអ្វីដែលអ្នកធ្វើសម្រាប់ពួកបងប្អូន និងពួកអ្នកដទៃដែរ នោះអ្នកក៏ធ្វើ ដោយស្មោះត្រង់គ្រប់ទាំងអស់ហើយ"។

(៣យ៉ូហាន១:៥)

Copyright © Gratia Dei Sola Media

## ១៦.៦.តើការស្មោះត្រង់ក្នុងគ្រួសារមានន័យយ៉ាងណា?

គឺជាការទទួលខុសត្រូវ សូម្បីតែចំពោះកិច្ចការតូចតាច ដូចជាធ្វើការងារផ្ទះ និងការសម្អាតបន្ទប់ខ្លួនឯងជាដើម ព្រះអម្ចាស់មានបន្ទូលថា៖ "អ្នកណាដែលស្មោះត្រង់ក្នុងការតូចបំផុត នោះក៏ឈ្មោះថាស្មោះត្រង់ក្នុងកិច្ចការធំ ហើយអ្នកណាដែលទុច្ចរិតក្នុងការ តូចបំផុត នោះក៏ទុច្ចរិតក្នុងការដ៏ធំដែរ"។ (លូកា១៦:១០)

## ១៦.៧.តើលទ្ធផលភ្លាមៗនៃទំនួលខុសត្រូវលើការងារផ្ទះរបស់ អ្នកនឹងមានអ្វីខ្លះ?

អ្នកនឹងឈ្នះបានទំនុកចិត្តពីឪពុកម្ដាយ អ្នកហើយក៏មិនបាច់ស្ដាប់សម្ដីច្រំដែលៗទៀតឡើយ គឺដូចជាបូជាចារ្យទុកចិត្តដល់ពួកជាងនៅក្នុងរជ្ជកាលព្រះបាទ យ៉ូអាសដូច្នោះដែរ "មួយទៀតគេមិនបានគិត នឹងពួកអ្នកដែលគេប្រគល់ប្រាក់នោះទៅឱ្យសម្រាប់ចំណាយ ដល់ពួកជាងដែលធ្វើការនោះទេ! ពីព្រោះអ្នកទាំងនោះបានប្រព្រឹត្ត ដោយចិត្តស្មោះត្រង់"។ (១ពង្សាវតារក្សត្រ ១២:១៥)

## ១៦.៨.តើភាពស្មោះត្រង់គឺជាគុណធម៌តបស្នងនៅក្នុងជីវិតនេះមែនទេ?

ពិតមែនហើយ "មនុស្សស្មោះត្រង់នឹងបានពរជាបរិបូរ តែអ្នក ណាដែលប្រញាប់ប្រញាល់ឱ្យបានជាអ្នកមាននោះនឹងមិនរួចចាកពីទោសឡើយ"។ (សុភាសិត ២៨:២០)

 Copyright © Gratia Dei Sola Media

# មេរៀនទី ១៧
# ភក្ដីភាព

**១៧.១.តើភក្ដីភាពជាគុណធម៌របស់គ្រីស្ទបរិស័ទមែនទេ?**

ពិតប្រាកដហើយ ប៉ុន្តែវាត្រូវបានគេនិយាយប្រៀបទៅនឹងសេចក្ដីស្រឡាញ់ និងភាពស្មោះត្រង់ចំពោះបុគ្គល ចំពោះពួកជំនុំ ឬប្រទេសជាតិ ជាពិសេសគឺនៅពេលណាដែលជួបការលំបាក ព្រះបាទសាឡូម៉ូនមានបន្ទូលថា៖ "មិត្តសម្លាញ់រមែងស្រឡាញ់គ្នានៅគ្រប់វេលា រីឯបងប្អូនក៏កើតមកសម្រាប់គ្រាលំបាកដែរ"។ (សុភាសិត ១៧:១៧)

**១៧.២.តើអ្នកអាចរៀនធ្វើជាមិត្តសម្លាញ់ដ៏ស្មោះត្រង់ពីអ្នកណា?**

រៀនពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាសម្លាញ់ដែលព្រះបាទសាឡូម៉ូនចង់សំដៅលើព្រះគ្រីស្ទពេលគាត់មានបន្ទូលថា៖ "អ្នកណា ដែលមានមិត្តភ័ក្ត្រច្រើន នោះនាំឱ្យវិនាសខ្លួនទេ ប៉ុន្តែមានមិត្តសម្លាញ់ម្យ៉ាងដែលនៅជាប់ជាងបងប្អូនទៅទៀត"។ (សុភាសិត ១៨:២៤)

**១៧.៣.តើមានន័យយ៉ាងណាដែលមានចិត្តភក្ដីឬស្មោះត្រង់ជួយមិត្តភ័ក្ដដែលគាត់កំពុងជួបការលំបាក?**

ត្រូវការពារគាត់ ដូចពេលយ៉ូណាថានការពារដាវីឌ ខណៈដែលស្ដេចសូលចង់សម្លាប់រូបលោក "ដូច្នេះយ៉ូណាថានក៏តំណាលសេចក្ដីយ៉ាងល្អពីដំណើរដាវីឌ ទូលដល់សូលជាបិតាថា សូមកុំឱ្យបិតាធ្វើបាបដល់ដាវីឌ ជាអ្នកបម្រើទ្រង់

Copyright © Gratia Dei Sola Media

ឡើយ ត្បិតគាត់មិនបានធ្វើខុសនឹងបិតាទេ ហើយការដែលគាត់បានធ្វើសោត នោះគឺសុទ្ធតែមានប្រយោជន៍ ដល់បិតាទាំងអស់ផង៉។ (១សាំយ៉ូអែល ១៩:៤)

**១៧.៤.តើការដែលមានចិត្តភក្ដីឬស្មោះត្រង់ចំពោះមិត្តភ័ក្រដែលប្រព្រឹត្តនោះមានន័យយ៉ាងណា?**

គឺត្រូវទូន្មានដោយសេចក្ដីស្រឡាញ់ "ត្បិតការដែលត្រូវបន្ទោសនៅកណ្ដាលជំនុំ នោះវិសេសជាងសេចក្ដីស្រឡាញ់លាក់កំបាំង។ របួសដែលមិត្តសម្លាញ់ធ្វើដល់យើង នោះតែងធ្វើដោយស្មោះត្រង់ទេ តែឯការថើបរបស់ខ្មាំងសត្រូវនោះជាសេចក្ដីបញ្ឆោតវិញ៉។ (សុភាសិត ២៧:៥-៦)

**១៧.៥.តើចិត្តភក្ដី ឬស្មោះត្រង់ចំពោះមនុស្សដែលលាក់ការសម្ងាត់នៅនឹងអ្នកមានន័យយ៉ាងណា?**

ត្រូវលាក់ការសម្ងាត់នោះឱ្យជិតត្បិត "អ្នកណាដែលដើរចុះឡើងនិយាយបកកេរគេនោះ ឈ្មោះថាបើកការអាថ៌កំបាំង តែអ្នកណាដែលមានចិត្តស្មោះត្រង់ នោះតែងគ្របបាំងរឿងរ៉ាវវិញ៉។ (សុភាសិត១១:១៣)

**១៧.៦.តើនៅក្នុងព្រះគម្ពីរមានគំរូនៃភក្ដីភាពចំពោះរដ្ឋាភិបាលទេ?**

ពិតជាមាន ដាវីឌបានទុកជីវិតឱ្យស្ដេចសូល ទោះបីជាស្ដេចសូលព្យាយាមតាមសម្លាប់លោកក៏ដោយ រួចលោកក៏និយាយទៅកាន់ស្ដេចសូលវិញថា៖ "មើល ថ្ងៃនេះឯងព្រះនេត្រទ្រង់ឃើញជាយ៉ាងណាហើយដែលព្រះយេហូវ៉ាបាន


Copyright © Gratia Dei Sola Media

ប្រគល់ទ្រង់មកក្នុងកណ្ដាប់ដៃនៃទូលបង្គំនៅក្នុងរអាងភ្នំនេះ ក៏មានអ្នកខ្លះប្រាប់ឱ្យទូលបង្គំសម្លាប់ទ្រង់ចោល តែទូលបង្គំបានប្រណីដល់ទ្រង់វិញ ដោយថាទូលបង្គំមិនព្រមលើកដៃទាស់នឹងចៅហ្វាយនៃទូលបង្គំទេ ត្បិតព្រះយេហូវ៉ាបានចាក់ប្រេងតាំងទ្រង់ហើយ៉។ (១សាំយ៉ូអែល២៤:១០)

## ១៧.៧.តើបទគម្ពីរផ្ដន្ទាចិត្តដែលគ្មានភក្ដីភាពទេ?

ពិតណាស់ ត្បិតព្រះបាទសាឡូម៉ូនមានបន្ទូលថា៖ "ការដែលទុកចិត្តពឹងដល់មនុស្សមិនស្មោះត្រង់ នៅគ្រាលំបាកនោះប្រៀបដូចជាធ្មេញបាក់ ហើយជើងដែលផ្លោះលាសចេញ៉។ (សុភាសិត២៥:១៩)

## ១៧.៨.តើយើងត្រូវមានភក្ដីភាពដើម្បីអ្វី?

ដើម្បីវិសាលភាពនៃភាពសុចរិត និងសេចក្ដីពិតត្បិតសេចក្ដីស្រឡាញ់ "មិនដែលអរសប្បាយនឹងសេចក្ដីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្ដីស្មោះត្រង់វិញ៉។ (១កូរិនថូស១៣:៦)

# មេរៀនទី ១៨
# របៀបរៀបរយ និង វិន័យ

**១៨.១.តើរបៀបរៀបរយជាគុណធម៌របស់គ្រីស្ទបរិស័ទមែនទេ?**

ពិតមែនហើយ លោកសាវ័កប៉ុលទូន្មានយើងថា៖ "ត្រូវតែធ្វើការទាំងអស់តាមបែបគួរសម ហើយដោយលំដាប់លំដោយផង"។ (១កូរិនថូស ១៤:៤០)

**១៨.២.តើវិន័យមានជាប់ពាក់ព័ន្ធនឹងរបៀបរៀបរយដែរមែនទេ?**

មែនហើយ មានវិន័យ គឺមានន័យថា មាយាទយើង ត្រូវតឹងរឹងនិងត្រូវមានរៀបរៀបរយ លោកសាវ័កប៉ុលស្គាល់ពីសារៈសំខាន់នៃការអប់រំ។ គាត់មានប្រសាសន៍ថា៖ "គឺអ្នកវាយដំរូបកាយអ្នកទាំងបង្ខំឱ្យចុះចូល ក្រែងក្រោយពេលដែលអ្នកបានប្រដៅមនុស្សឯទៀតហើយ នោះខ្លួនអ្នកត្រូវចោលចេញវិញ" ។ (១កូរិនថូស ៩:២៧)

**១៨.៣.តើជីវិតដែលគ្មានរបៀបរៀបរយជាជីវិតបាបមែនទេ?**

មែនហើយ លោកសាវ័កប៉ុលបានប្រាប់ដល់ពួកជំនុំនៅក្នុងថែស្សាឡូនីច ឱ្យដកខ្លួនចេញពីបងប្អូនដែលគ្មានរបៀបរៀបរយ "ឥឡូវនេះបងប្អូនអើយ យើងអ្នកសូមផ្តាំមកអ្នករាល់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងថា ចូរថយចេញឱ្យផុតពីគ្រប់ទាំងបងប្អូនណាដែលប្រព្រឹត្តខុសរបៀប ហើយមិនស្តាប់តាមបញ្ញាត្តិដែលទទួលពីយើងខ្ញុំ"។ (២ថែស្សាឡូនិច ៣:៦)


Copyright © Gratia Dei Sola Media

## ១៨.៤.តើសំខាន់ដែរទេដែលត្រូវមានរបៀបក្នុងជីវិតរស់នៅ?

ពិតមែនហើយ ព្រះអម្ចាស់មានបន្ទូលថា "អ្នកណាដែលថ្វាយដង្វាយជាសេចក្ដីអរព្រះគុណ នោះក៏លើកដម្កើងអញដែរ ហើយអញនឹងសម្ដែងសេចក្ដីសង្គ្រោះរបស់ព្រះដល់អ្នកណាដែលរៀបផ្លូវរបស់ខ្លួនឱ្យត្រង់"។
(ទំនុកដម្កើង៥០:២៣)

## ១៨.៥.តើព្រះយេស៊ូវគ្រីស្ទបានបង្ហាញយើងអំពីគំរូនៃការរស់នៅដោយមានរបៀបរៀបរយដែរឬទេ?

ពិតជាមាន គឺនៅពេលដែលព្រះអង្គចែកអាហារដល់មនុស្សប្រាំពាន់នាក់ "នោះទ្រង់បង្គាប់ឱ្យពួកសិស្សប្រាប់គេឱ្យអង្គុយលើស្មៅខ្ចីហើយពួកគេក៏អង្គុយដោយជួរ ក្នុងមួយជួរហាសិបនាក់ ទាំងអស់មានមួយរយជួរ"។
(ម៉ាកុស៦:៣៩-៤០

## ១៨.៦.តើព្រះយេស៊ូវគ្រីស្ទបានបង្ហាញយើងអំពីគំរូនៃការរស់នៅដោយមានការអប់រំដែរឬទេ?

ពិតជាមានទម្លាប់ប្រចាំថ្ងៃរបស់ព្រះអង្គមែន គឺក្រោកឡើងអធិស្ឋានរាល់ពេលព្រឹក លោកសាវ័កម៉ាកុសប្រាប់យើងថាៈ "កាលនៅងងឹតមិនទាន់ភ្លឺស្រាងនៅឡើយ នោះទ្រង់តើនឡើងយាងចេញទៅឯទីស្ងាត់ហើយអធិស្ឋាននៅទីនោះ"។
(ម៉ាកុស១:៣៥)

Copyright © Gratia Dei Sola Media

## ១៨.៧.ចូរប្រាប់ឈ្មោះវិធីមួយដែលយើងអាចបណ្តុះជីវិតគ្រីស្ទបរិស័ទដែលមានវិន័យ?

ខ្ញុំសូមធ្វើការតាំងចិត្តចំពោះព្រះអម្ចាស់ថា៖ "ឱព្រះយេហូវ៉ាអើយ នៅពេលព្រឹកទ្រង់នឹងឮសម្លេងរបស់ទូលបង្គំ គឺនៅពេលព្រឹកទូលបង្គំនឹងទូលដល់ទ្រង់ ដោយលំដាប់ព្រមទាំងរក្សាពេលចាំយាមផង"។ (ទំនុកដម្កើង៥:៣)

## ១៨.៨.តើអ្នកអាចបណ្តុះឱ្យមានរបៀបរៀបរយនៅក្នុងជីវិតគ្រីស្ទបរិស័ទបានយ៉ាងដូចម្តេច?

ខ្ញុំនឹងព្យាយាមឱ្យមានរបៀបរៀបរយហ្មត់ចត់ ហើយស្អាតបាតក្នុងគ្រប់កិច្ចការដែលអ្នកធ្វើ ទាំងនៅផ្ទះ នៅសាលារៀន និងនៅក្នុងព្រះវិហារផង "ត្បិតព្រះទ្រង់មិនជាព្រះនៃសេចក្តីវឹកវរទេ"។ (១កូរិនថូស ១៤:៣៣)

 Copyright © Gratia Dei Sola Media

# មេរៀនទី ១៩
# ការអត់ធ្មត់ និង ការទ្រាំទ្រលំបាក

**១៩.១.តើភាពអត់ធ្មត់ (ការរង់ចាំដោយភាពចិត្តរីករាយ) និងការទ្រាំទ្រលំបាក (ការទ្រាំទ្រនឹងភាពឈឺចាប់ ដោយចិត្តតក្រេកអរ) គឺជាសីលធម៌ដ៏សំខាន់របស់គ្រីស្ទបរិស័ទមែនទេ?**

ពិតមែនហើយ លោកសាវ័កប៉ុលបានអធិស្ឋានឱ្យពួកជំនុំនៅក្រុងកូល៉ុស ដោយសូមឱ្យពួកគេ៖ "បានគ្រប់ទាំងព្រះចេស្តាចម្រើនកម្លាំងតាមឫទ្ធិបារមីដ៏ឧត្ដមរបស់ទ្រង់ ដើម្បីឱ្យបានចេះទ្រាំទ្រ ហើយអត់ធន់គ្រប់យ៉ាងដោយអំណរ"។ (កូល៉ុស១:៩-១១)

**១៩.២.តើយើងត្រូវពីការអត់ធ្មត់ និងការទ្រាំទ្រលំបាកពីអ្នកណាជាពិសេស?**

គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ ត្បិតអ្នកសរសេរសំបុត្រទៅកាន់ពួកហេព្រើរ មានប្រសាសន៍ថា៖ "ដូច្នេះ ដែលមានស្មរបន្ទាល់មួយហ្វូងធំម្ល៉េះនៅព័ទ្ធជុំវិញយើង នោះត្រូវឱ្យយើងចោលអស់ទាំងបន្ទុក និងអំពើបាប ដែលរុំយើងជុំវិញជាងាយម្ល៉េះនោះចេញ ហើយរត់ទៅក្នុងទីប្រណាំងដែលនៅមុខយើងដោយអំណត់ ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្ដើម ហើយជាមេសម្រេចសេចក្ដីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំលើឈើឆ្កាង ទាំងមើលងាយចំពោះសេចក្ដីអាម៉ាស់នោះ ឱ្យតែបានសេចក្ដីអំណរដែលនៅចំពោះទ្រង់ រួចទ្រង់ក៏គង់នៅខាងស្ដាំបល្ល័ង្កនៃព្រះ"។

Copyright © Gratia Dei Sola Media

(ហេព្រើរ ១២:១-២)

**១៩.៣.តើព្រះយេស៊ូវគ្រីស្ទបានបង្ហាញភាពអត់ធ្មត់ និងការទ្រាំទ្រលំបាកយ៉ាងដូចម្ដេច?**

"ទ្រង់ត្រូវគេសង្កត់សង្កិនហើយធ្វើទុក្ខ តែទ្រង់មិនបានហើបព្រះឱស្ឋសោះ គឺដូចជាកូនចៀមដែលគេដឹកយកទៅសម្លាប់ ហើយដូចជាចៀម ដែលនៅចំពោះអ្នកកាត់រោមយ៉ាងណា ទ្រង់ក៏មិនបានហើបព្រះឱស្ឋសោះយ៉ាងនោះដែរ"។ (អេសាយ ៥៣:៧)

**១៩.៤.តើយើងអាចរៀនពីការអត់ធ្មត់និងការទ្រាំទ្រលំបាកពីអ្នកណាទៀត?**

ពីលោកយ៉ូប និងពួកហោរាដទៃទៀត ត្បិតសាវ័កយ៉ាកុបមានប្រសាសន៍ថា "បងប្អូនអើយ ចូរយកពួកហោរាដែលបានទាយដោយនូវព្រះនាមព្រះអម្ចាស់ ទុកជាគំរូពីសេចក្ដីទុក្ខលំបាក និងពីសេចក្ដីអត់ធ្មត់ចុះ មើល យើងហៅពួកអ្នកទ្រាំទ្រថាជាអ្នកមានពរ ចុះអ្នករាល់គ្នាបានឮនិយាយពីសេចក្ដីអត់ធ្មត់របស់លោកយ៉ូបទៅហើយ"។ (យ៉ាកុប ៥:១០-១១)

**១៩.៥.តើគ្រីស្ទបរិស័ទត្រូវប្រឈមនឹងការទ្រាំទ្រលំបាកដូចម្ដេច?**

គឺត្រូវទ្រាំទ្រដោយអំណរ និងដោយអត់ធ្មត់ ត្បិតលោកសាវ័កយ៉ាកុបបានមានប្រសាសន៍ថា "បងប្អូនអើយ កាលណាមានសេចក្ដីល្បួងផ្សេងៗ នោះត្រូវរាប់ជាសេចក្ដីអំណរសព្វគ្រប់វិញ ដោយដឹងថាការល្បងលមើលសេចក្ដីជំនឿ

 Copyright © Gratia Dei Sola Media

នៃអ្នករាល់គ្នានោះនាំបង្កើតឱ្យមានសេចក្តីខ្ជាប់ខ្ជួន ចូរទុកឱ្យសេចក្តីខ្ជាប់ខ្ជួននោះ បានធ្វើការឱ្យសម្រេចពេញលេញចុះ ដើម្បីឱ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ"។

(យ៉ាកុប១:២-៤, រ៉ូម ៥:៣-៤ និង ១ពេត្រុស ២:២០)

## ១៩.៦.តើគួរឈប់ធ្វើអំពើល្អព្រោះមនុស្សមិនចេះអរគុណមែនទេ?

ទេ! ត្បិតលោកសាវ័កប៉ុលមានប្រសាសន៍ថា៖ "កុំឱ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ ត្បិតបើមិនរសាយចិត្តទេ លុះដល់កំណត់ យើងនឹងច្រូតបានហើយ"។ (កាឡាទី៦:៩)

## ១៩.៧.ការរស់នៅជាគ្រីស្ទបរិស័ទនិងការសិក្សាពីគោលជំនឿគឺពិតជាលំបាកមែនតើអ្នកត្រូវធ្វើយ៉ាងណា?

គឺត្រូវអត់ធ្មត់នៅក្នុងព្រះអម្ចាស់ "បើមនុស្សនឹងសង្ឃឹមដល់ ហើយរង់ចាំសេចក្តីសង្គ្រោះរបស់ព្រះយេហូវ៉ា ឥតបារម្ភព្រួយនោះល្អហើយ ឯការដែលមនុស្សនឹងទទួលរងនឹមក្នុងការដែលនៅវ័យក្មេងនោះក៏ល្អដែរ"។ (បរិទេវ៣:២៦-២៧)

## ១៩.៨.មើលទៅព្រះជាម្ចាស់ហាក់ដូចជាស្តាប់មិនឮពាក្យទំនួញរបស់អ្នកសោះ តើអ្នកត្រូវធ្វើយ៉ាងណា?

ត្រូវរង់ចាំព្រះអម្ចាស់ដោយសេចក្តីអំណត់ "ខ្ញុំបានរង់ចាំព្រះយេហូវ៉ាដោយអំណត់ ទ្រង់ក៏បានផ្ទៀងព្រះកាណ៌មកស្តាប់ ហើយទទួលតាមសម្រែករបស់ខ្ញុំ"។

(ទំនុកដម្កើង៤០:១, ៣៧:៧)

Copyright © Gratia Dei Sola Media

# មេរៀនទី ២០
# សេចក្តីឧស្សាហ៍ និង ភាពឈ្លាសវៃ

**២០.១.តើសេចក្តីឧស្សាហ៍ (ខំប្រឹងប្រែងធ្វើការអ្វីអោយបានល្អ) និងភាពឈ្លាសវៃ ជាតម្លៃនៃគ្រីស្ទបរិស័ទដែរមែនទេ?**

មែនហើយ ត្បិតបទគម្ពីរចែងបង្គាប់មកថា៖ "ការអ្វីដែលដៃឯងអាចធ្វើបាន ចូរធ្វើឱ្យអស់ពីកម្លាំងចុះ"។(សាស្តា ៩:១០)

**២០.២.តើបទគម្ពីរណែនាំឱ្យយើងរៀនពីសេចក្តីឧស្សាហ៍ និងភាពឈ្លាសវៃចេញពីអ្វី?**

គឺពីសត្វស្រមោច ព្រះបាទសាឡូម៉ូនទ្រង់មានបន្ទូលថា៖ "ចូរទៅមើលសត្វស្រមោច ចូរទៅមើលផ្លូវទាំងប៉ុន្មានរបស់វាហើយមានប្រាជ្ញាឡើង វាគ្មាននាយ គ្មានអ្នកកាន់កាប់ការ ឬអ្នកគ្រប់គ្រងឡើយ គង់តែវាផ្គត់ផ្គង់អាហារវានៅខែប្រាំង ហើយក៏ប្រមូលស្បៀងទុកនៅក្នុងរដូវចម្រូតផង"។ (សុភាសិត៦:៦-៨)

**២០.៣.តើអ្នកត្រូវធ្វើគ្រប់ភារកិច្ចរបស់អ្នកទាំងនៅផ្ទះ នៅសាលារៀន និងនៅព្រះវិហារដោយមានឥរិយាបទបែបណា?**

"ហើយការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឱ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ"។ (កូល៉ុស៣:២៣)

 Copyright © Gratia Dei Sola Media

## ២០.៤.តើយើងទទួលបានការលើកចិត្តអ្វីខ្លះសម្រាប់សេចក្ដីឧស្សាហ៍ និងភាពឈ្លាសវៃដែលយើងមាន?

យើងអាចបម្រើព្រះជាម្ចាស់ ដោយសម្បត្តិដែលយើងមាន ឧទាហរណ៍ថា យើងអាចជួយបងប្អូនដែលខ្វះខាត ត្បិតលោកសាវ័កប៉ុលមានប្រសាសន៍ថា៖ "អ្នកណាដែលធ្លាប់លួចត្រូវឈប់លួចទៅស៊ូឱ្យអ្នកនោះ ទ្រាំនឿយហាត់ជាជាងទាំងធ្វើការល្អដោយដៃខ្លួនវិញ ដើម្បីឱ្យមានអ្វីនឹងចែកដល់អ្នកណាដែលត្រូវការផង"។
(អេភេសូរ ៤:២៨, កិច្ចការ ២០:៣៥)

## ២០.៥.តើព្រះអម្ចាស់ប្រទានរង្វាន់ដល់មនុស្សដែលមានសេចក្ដីឧស្សាហ៍ក្នុងជីវិតនេះដែរឬទេ?

ពិតជាប្រទាន ត្បិតព្រះបាទសាឡូម៉ូនមានបន្ទូលថា៖ "ឯងដែលឃើញមនុស្សខ្នះខ្នែង ក្នុងការរកស៊ីរបស់ខ្លួនឬ អ្នកនោះនឹងបានឈរនៅចំពោះស្ដេច មិនត្រូវឈរនៅចំពោះមនុស្សដែលឥតបណ្ដាសក្ដិឡើយ"។ (សុភាសិត ២២:២៩)

## ២០.៦.អ្វីទៅជាលទ្ធផលនៃភាពខ្ជិលច្រអូស?

ភាពក្រីក្រ និងជីវិតវេទនា ត្បិតព្រះបាទសាឡូម៉ូនមានបន្ទូលថា៖ "ដេកបន្តិច ងោកបន្តិច ឱបដៃនឹងដេកបន្តិច យ៉ាងនោះសេចក្ដីកំសត់ទុគ៌តរបស់ឯង នឹងលោមកដល់ដូចជាចោរប្លន់ ព្រមទាំងសេចក្ដីខ្វះខាតដូចជាមនុស្សកាន់អាវុធ"។ (សុភាសិត២៤:៣៣-៣៤)

Copyright © Gratia Dei Sola Media

## ២០.៧.តើយើងត្រូវគេតម្រូវធ្វើការដោយឈ្លាសវៃរាល់តែថ្ងៃទេ?

ទេ! យើងត្រូវសម្រាកនៅថ្ងៃឈប់សម្រាក ហើយរក្សាថ្ងៃនោះទុកឱ្យបានជាបរិសុទ្ធ ព្រះអម្ចាស់មានបន្ទូលនៅក្នុងបញ្ញាត្តិទី៤ថា៖ "តែងថ្ងៃទី៧ គឺជាថ្ងៃឈប់សម្រាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើអ្វីឱ្យសោះ ទោះខ្លួនឯង ឬកូនប្រុសកូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះសត្វរបស់ឯងឬអ្នកដទៃដែលនៅផ្ទះឯងក្តី"។ (និក្ខមនំ២០:១០)

## ២០.៨.មានន័យថា យើងមិនត្រូវឈ្លាសវៃនៅថ្ងៃឈប់សម្រាកទេមែនទេ?

ទេ! មិនមែនទេ យើងត្រូវរក្សាភាពឈ្លាសវៃនៅក្នុងការគោរពស្រឡាញ់ដល់ព្រះ និងក្នុងកិច្ចការនៃព្រះគុណ ឧទាហរណ៍ យើងត្រូវអធិស្ឋានដូចជា លោកសាវ័កប៉ុលមានប្រសាសន៍ថា៖ "ចូរអរសប្បាយដោយមានសង្ឃឹម ចូរអត់ធន់ក្នុងសេចក្តីទុក្ខលំបាក ចូរឱ្យខ្ជាប់ខ្ជួនក្នុងសេចក្តីអធិស្ឋាន"។ (រ៉ូម១២:១២)

 Copyright © Gratia Dei Sola Media

# មេរៀនទី ២១
# ប្រាជ្ញា (គតិបណ្ឌិត)

## ២១.១.តើប្រាជ្ញាគឺជាតម្លៃរបស់គ្រីស្ទបរិស័ទដែរមែនទេ?

មែនហើយ ប្រាជ្ញា គឺជាការគិតអំពីផ្លូវរបស់ព្រះជាម្ចាស់ ត្បិតព្រះបាទដាវីឌមានបន្ទូលថា៖ "ឯសេចក្តីកោតខ្លាច នោះគឺជាដើមចមនៃប្រាជ្ញាអស់អ្នកដែលកាន់តាម នោះមានយោបល់ល្អ សេចក្តីសរសើរនៃទ្រង់ជាប់នៅអស់កល្បជានិច្ច។ (ទំនុកដម្កើង ១១១:១០)

## ២១.២.ចំណេះដឹងយើងអាចរកបាន ប៉ុន្តែតើយើងអាចរកបានប្រាជ្ញាបានដែរឬទេ?

គឺពិតជាអាចរកបាន ព្រះបាទសាឡូម៉ូនទ្រង់មានបន្ទូលថា៖ "ប្រាជ្ញាជាសំខាន់លេខ១ ដូច្នេះចូរខំឱ្យបានប្រាជ្ញាចុះ អើកំពុងដែលខំឱ្យបានរបស់ផ្សេងៗ នោះចូរខំឱ្យបានយោបល់ផង"។ (សុភាសិត ៤:៧)

## ២១.៣.តើអ្នកអាចរកបានប្រាជ្ញាដោយរបៀបណា?

អ្នកអាចរកបានប្រាជ្ញាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺតាមរយៈការអាន និងការស្តាប់ "ត្បិតព្រះយេហូវ៉ាទ្រង់ប្រទានឱ្យមានប្រាជ្ញា ឯតំរិះនិងយោបល់នោះចេញពីព្រះឱស្ឋទ្រង់មក"។ (សុភាសិត២:៦, ៥:១)

Copyright © Gratia Dei Sola Media

**២១.៤.តើការអាន និងការស្តាប់ព្រះបន្ទូលព្រះគ្រប់គ្រាន់នឹងអាចរកបានប្រាជ្ញាហើយឬនៅ?**

ទេ! មិនទាន់គ្រប់គ្រាន់នៅឡើយទេ អ្នកត្រូវទូលសុំប្រាជ្ញាពីព្រះទៀត ដូចលោកសាវ័កយ៉ាកុប មានប្រសាសន៍ថា៖ "តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសុំដល់ព្រះដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ ដោយសទ្ធាឥតបន្ទោសផងនោះទ្រង់នឹងប្រទានឱ្យ"។(យ៉ាកុប ១:៥, ២កូរិនថូស ១:៧-១២)

**២១.៥.តើធ្វើម្តេចទើបអ្នកអាចរស់នៅដោយប្រាជ្ញាបាន?**

ដោយស្តាប់តាមបញ្ញាត្តិព្រះជាម្ចាស់ "សេចក្តីបង្គាប់របស់ទ្រង់ ក៏ធ្វើឱ្យទូលបង្គំមានប្រាជ្ញាលើសជាងខ្មាំងសត្រូវ ត្បិតបាននៅជាប់ជាមួយនឹងទូលបង្គំជាដរាប"។
(ទំនុកដម្កើង ១១៩:៩៨)

**២១.៦.ចុះបើអ្នកមិនដឹងថាបញ្ញាត្តិមួយណាអ្នកត្រូវយកមកអនុវត្តក្នុងកាលៈទេសៈបែបណា ហើយគ្មានអ្នកណាសួរទៀតនោះតើយ៉ាងណាវិញ?**

អ្នកនឹងអធិស្ឋាន ហើយអ្នកនឹងពិចារណាពីអ្វីដែលព្រះអង្គឱ្យអ្នកត្រូវធ្វើ នៅក្នុងកាលៈទេសៈនោះ ត្បិត"សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ាជាដើមចមនៃប្រាជ្ញា រីឯការដែលស្គាល់ដល់ព្រះដ៏បរិសុទ្ធ នោះគឺជាយោបល់"។
(សុភាសិត ៩:១០, សុភាសិត ១:៧)


Copyright © Gratia Dei Sola Media

**២១.៧.តើឪពុកម្ដាយរបស់អ្នកជួយឱ្យអ្នកលូតលាស់ខាងឯប្រាជ្ញាយ៉ាងដូចម្ដេច?**

ពួកគាត់ដាក់វិន័យអ្នក នៅពេលដែលអ្នកប្រព្រឹត្តបែបល្ងីល្ងើ ឬប្រព្រឹត្តបាប "រំពាត់ និងសេចក្ដីប្រៀនប្រដៅ រមែងឱ្យកើតមានប្រាជ្ញា តែកូនណាដែលបណ្ដោយឱ្យប្រព្រឹត្តតាមអំពើចិត្តនោះ តែងធ្វើឱ្យម្ដាយមានសេចក្ដីខ្មាស់"។ (សុភាសិត ២៩:១៥)

**២១.៨.តើប្រាជ្ញាមានសារៈសំខាន់សម្រាប់ជីវិតរីករាយរបស់គ្រីស្ទបរិស័ទដែរឬទេ?**

ពិតមែនហើយ "សប្បាយហើយអស់អ្នកណាដែលរកបានប្រាជ្ញាហើយអ្នកណាដែលខំប្រឹងទាល់តែបានយោបល់"។ (សុភាសិត៣:១៣)

**២១.៩.តើការទំនាក់ទំនងល្អជាមួយមិត្តភ័ក្តិរបស់អ្នកត្រូវការប្រាជ្ញាដែរឬទេ?**

ពិតមែនហើយ "ត្បិតអ្នកណាដែលមើលងាយចំពោះអ្នកជិតខាងខ្លួននោះឥតមានប្រាជ្ញាទេ តែអ្នកណាមានយោបល់រមែងនៅស្ងៀមវិញ"។ (សុភាសិត ១១:១២)

Copyright © Gratia Dei Sola Media

# មេរៀនទី ២២
# ភាពបរិសុទ្ធផ្ទាល់ខ្លួន

## ២២.១. តើពាក្យថាបរិសុទ្ធមានន័យដូចម្ដេចចំពោះអ្នក?

វាគឺជាការរក្សាមាយាទខ្លួនឯង នៅក្នុងពាក្យសម្ដី ក្នុងការប្រព្រឹត្តនិងការគិត តាមបែបមួយដែលធ្វើឱ្យអ្នកកាន់តែដូចព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយខុសពីលោកិយ លោកសាវ័កពេត្រុសបានបង្គាប់ថា៖ "ចូរឱ្យឯងរាល់គ្នា បានជាបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះដែលបានហៅអ្នករាល់គ្នា ទ្រង់បរិសុទ្ធដែរ ត្បិតមានសេចក្ដីចែងទុកមកថា ចូរឱ្យឯងរាល់គ្នាបានបរិសុទ្ធ ត្បិតអញជាបរិសុទ្ធ"។ (១ពេត្រុស១:១៥-១៦)

## ២២.២.តើមិនមែនគ្រីស្ទបរិស័ទគ្រប់គ្នាសុទ្ធតែបរិសុទ្ធរួចជាស្រេចក្នុងព្រះគ្រីស្ទយេស៊ូវមែនទេ?

មែនហើយ យើងគ្រប់គ្នាត្រូវបានរាប់ជាសុចរិតក្នុងព្រះគ្រីស្ទ ដូច្នេះហើយបានជាយើងត្រូវគេហៅថា "ពួកបរិសុទ្ធ" ប៉ុន្តែយើងមានទំនួលខុសត្រូវ ក្នុងការរស់នៅក្នុងជីវិតដ៏បរិសុទ្ធ អ្នកសរសេរសំបុត្រ ទៅកាន់ពួកហេព្រើរមានប្រសាសន៍ថា "ចូរដេញតាមសេចក្ដីមេត្រី ចំពោះមនុស្សទាំងអស់ចុះ ហើយឱ្យបានញែកជាបរិសុទ្ធដែរ បើអ្នកណាគ្មានសេចក្ដីបរិសុទ្ធនោះមិនដែលឃើញព្រះអម្ចាស់ឡើយ"។ (ហេព្រើរ១២:១៤)


Copyright © Gratia Dei Sola Media

## ២២.៣.តើមនុស្សម្នាក់អាចត្រូវបានរាប់ជាសុចរិតដោយគ្មានភាពបរិសុទ្ធដែរឬទេ?

ទេ! មិនអាចទេ មនុស្សដែលត្រូវបានរាប់ជាសុចរិតនៅក្នុងព្រះគ្រីស្ទ ក៏នឹងលូតលាស់ក្នុងការញែកជាបរិសុទ្ធ ឬភាពបរិសុទ្ធ។ មនុស្សដែលប្រកាសថាខ្លួនសុចរិត តែគ្មានភាពបរិសុទ្ធផ្ទាល់ខ្លួន គឺជាមនុស្សកុហក លោកសាវ័កប៉ុលមានប្រសាសន៍ថា៖ "ត្បិតអ្នករាល់គ្នាដឹងថា គ្មានមនុស្សកំផិត ឬស្មោគគ្រោកឬលោភ គឺជាមនុស្សដែលថ្វាយបង្គំរូបព្រះ ដែលនឹងគ្រងមរតកក្នុងនគរនៃព្រះគ្រីស្ទ ហើយនៃព្រះផងបានឡើយ"។ (អេភេសូរ៥:៥)

## ២២.៤.តើមនុស្សគ្រប់គ្នាត្រូវកើតជាថ្មី ដើម្បីលូតលាស់នៅក្នុងភាពសុចរិតមែនទេ?

មែនហើយ មនុស្សដែលត្រូវបានរាប់ជាសុចរិត គឺជាមនុស្សដែលបានកែខ្លួនដែរ លោកសាវ័កប៉ុលមានប្រសាសន៍ទៅកាន់មនុស្សដែលកែខ្លួន ពេលដែលលោកនិយាយថា៖ "តែឥឡូវនេះ ដែលព្រះបានប្រោសពីបាបហើយ អ្នករាល់គ្នាបានត្រឡប់ជាបាវបម្រើដល់ទ្រង់ នោះអ្នករាល់គ្នាបានផលខាងឯសេចក្តីបរិសុទ្ធវិញ ហើយទីបំផុតនៃអំពើទាំងនោះគឺជាជីវិតអស់កល្បជានិច្ចផង"។ (រ៉ូម៦:២២)

Copyright © Gratia Dei Sola Media

## ២២.៥.តើអ្នកអាចលូតលាស់ខាងភាពបរិសុទ្ធបានយ៉ាងដូចម្ដេច?

គឺតាមរយៈការអាន និងស្ដាប់ព្រះបន្ទូលរបស់ព្រះ ត្បិតព្រះយេស៊ូវអធិស្ឋានថា "សូមញែកគេជាបរិសុទ្ធ ដោយសារសេចក្ដីពិតនៃទ្រង់ ឯសេចក្ដីពិត គឺជាព្រះបន្ទូលរបស់ទ្រង់" (យ៉ូហាន ១៧:១៧) រីឯលោកសាវ័កប៉ុលមានប្រសាសន៍ថា៖ "គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឱ្យតែងទេ ក៏មានប្រយោជន៍ សម្រាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត ដើម្បីឱ្យអ្នកសំណព្វរបស់ព្រះជាម្ចាស់បានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសម្រាប់នឹងធ្វើការល្អគ្រប់មុខ"។ (២ធីម៉ូថេ៣:១៦-១៧)

## ២២.៦.ក្រៅពីការអាន និងការស្ដាប់ព្រះបន្ទូលព្រះ តើអ្នកត្រូវធ្វើអ្វីខ្លះទៀត ដើម្បីឱ្យបានលូតលាស់នៅក្នុងភាពបរិសុទ្ធនេះ?

អ្នកត្រូវយកព្រះបន្ទូលនោះមកអនុវត្ត សាវ័កប៉ុលបានមានប្រសាសន៍ថា "ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នាដោយសេចក្ដីមេត្តាករុណានៃព្រះ ឱ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃយើងរាល់គ្នាដែលមានទំនង កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញដោយគំនិតបានកែប្រែជាថ្មីឡើង ដើម្បីនឹងអាចមើលឃើញឱ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អស្រួលទទួលហើយគ្រប់លក្ខណ៍ផង"។ (រ៉ូម១២:១-២)

 Copyright © Gratia Dei Sola Media

# មេរៀនទី ២៣
# ការប្រមាណខ្លួន ឬការទប់ចិត្តខ្លួនឯង

## ២៣.១.តើការប្រមាណខ្លួន គឺជាគុណធម៌នៃគ្រីស្ទបរិស័ទមែនទេ?

មែនហើយ វាគឺជាលក្ខណៈសម្បត្តិម្យ៉ាងដែលគ្រីស្ទបរិស័ទត្រូវបណ្តុះឱ្យមាន សាវ័កពេត្រុស បានមានប្រសាសន៍ថា៖ "ហើយដោយហេតុនោះ បានជាត្រូវឱ្យអ្នករាល់គ្នាបន្ថែមឱ្យមានសេចក្តីឧស្សាហ៍ដែរ ដើម្បីឱ្យសេចក្តីជំនឿ បានទៀងត្រង់ឱ្យសេចក្តីទៀងត្រង់បានគំរិះ ឱ្យគំរិះចេះអត់សង្កត់ឱ្យសេចក្តីអត់សង្កត់បានខ្ជាប់ខ្ជួន ឱ្យសេចក្តីខ្ជាប់ខ្ជួនបានចេះគោរពប្រតិបត្តិដល់ព្រះ ឱ្យសេចក្តីគោរពប្រតិបត្តិបានចេះរាប់អានគ្នាធ្វើជាបងប្អូន ហើយឱ្យសេចក្តីរាប់អានគ្នាបានសេចក្តីស្រឡាញ់ថែមទៀត ត្បិតបើសិនមានសេចក្តីទាំងនោះចម្រើនឡើងក្នុងចិត្តអ្នករាល់គ្នាហើយ នោះអ្នករាល់គ្នាមិននៅទំនេរ ឬឥតផលខាងដំណើរស្គាល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នាឡើយ"។
(២ពេត្រុស ១:៥-៨)

## ២៣.២.តើការប្រមាណខ្លួន ឬការទប់ចិត្តខ្លួនឯង គឺជាសញ្ញានៃព្រះគុណមែនទេ?

មែនហើយ មនុស្សដែលបានកើតជាថ្មីនឹងដឹងថាត្រូវគ្រប់គ្រងចំណង់ចិត្តយ៉ាងដូចម្តេច និងសេចក្តីប្រាថ្នារបស់ខ្លួនដោយរបៀបណា "ត្បិតផលផ្លែនៃព្រះវិញ្ញាណវិញនោះគឺសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ ស្លូតបូត

Copyright © Gratia Dei Sola Media

ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីទាំងនេះទេ"។ (កាឡាទី៥:២២-២៣)

## ២៣.៣.តើអ្នកអាចបណ្តុះការប្រមាណខ្លួននៅក្នុងជីវិតអ្នកយ៉ាងដូចម្តេច?

តាមរយៈការចងចាំទុកនៅក្នុងចិត្តថា អ្នកជាកម្មសិទ្ធរបស់ព្រះគ្រីស្ទ សាវ័កប៉ុលមានប្រសាសន៍ថា៖ "ត្រូវប្រដាប់ខ្លួនដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញ ហើយកុំឱ្យផ្គត់ផ្គង់ដើម្បីនឹងបំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមឡើយ"។ (រ៉ូម១៣:១៤)

## ២៣.៤.តើអ្នកណាដែលជាឧទាហរណ៍ដ៏ល្អ តើយើងអាចនឹងរៀនពីការប្រមាណខ្លួន ឬការទប់ចិត្តខ្លួនឯងនោះ ពីអ្នកណា?

គឺលោកហោរាដានីយ៉ែល "ត្បិត...ដានីយ៉ែលបានសម្រេចក្នុងចិត្តថា មិនព្រមឱ្យខ្លួនសៅហ្មង ដោយអាហាររបស់ស្តេច ឬដោយស្រាទំពាំងបាយជូរ ដែលទ្រង់ធ្លាប់សោយនោះឡើយ បានជាលោកសុំដល់ចៅហ្វាយ លើពួកកំរៀរដើម្បីមិនឱ្យខ្លួនត្រូវសៅហ្មងទៅ"។ (ដានីយ៉ែល១:៨)

## ២៣.៥. តើអ្នកត្រូវអនុវត្តការទប់ចិត្តខ្លួនឯងដូចជាកូនក្មេង នៅក្នុងផ្នែកណាមួយ?

គឺនៅក្នុងកន្លែងកំសាន្តដែលបណ្តែតបណ្តោយជ្រុល នាំឱ្យខ្ញុំប្រព្រឹត្តបាបទាស់នឹងព្រះជាម្ចាស់ ខ្ជះខ្ជាយពេលវេលាឬបំពានលើរូបកាយរបស់ខ្ញុំ៖ ឧទាហរណ៍ដូចជា តាមរយៈ

 Copyright © Gratia Dei Sola Media

ការមើលទូរទស្សន៍ ការលេងសើចច្រើនជ្រុល ឬសូម្បីតែការបរិភោគជាតិស្ករច្រើនជ្រុលពេក។ ព្រះបាទសាឡូម៉ូនទ្រង់មានបន្ទូលថា៖ "តើឯងរកឃ្មុំបានហើយឬ ចូរបរិភោគតែល្មមសមគួរចុះក្រែងបរិភោគឆ្អែតទៅនឹងក្អួតចេញវិញ"។ (សុភាសិត ២៥:១៦)

**២៣.៦.តើអ្នកត្រូវរៀនទប់ចិត្តខ្លួនឯង ពេលទាក់ទងជាមួយអ្នកដទៃដែរឬទេ?**

ពិតមែនហើយ ខ្ញុំត្រូវរៀនទប់កំហឹង និងអណ្តាតរបស់ខ្ញុំ ពេលដែលមានអ្នកណាធ្វើឱ្យខ្ញុំខឹង ព្រះបាទសាឡូម៉ូនមានបន្ទូលថា៖ "ពួកល្ងីល្ងើសម្តែងចេញ អស់ទាំងកំហឹងរបស់ខ្លួន តែមនុស្សមានប្រាជ្ញាគេទប់ចិត្ត ហើយរម្ងាប់ចេញវិញ"។ (សុភាសិត ២៩:១១)

**២៣.៧.ក្នុងជីវិតអ្នក តើផ្នែកណាមួយដែលអ្នកត្រូវអនុវត្តការទប់ចិត្តខ្លួនឯង យ៉ាងប្រុងប្រយ័ត្នជាពិសេស ខណៈដែលអ្នកកាន់តែចម្រើនវ័យឡើង?**

គឺត្រង់ភាពបរិសុទ្ធខាងរូបកាយ ត្បិតលោកសាវ័កប៉ុលមានប្រសាសន៍ថា "ចូររត់ពីការសហាយស្មន់ចេញ គ្រប់ទាំងអំពើបាបណាដែលមនុស្សប្រព្រឹត្ត នោះនៅខាងក្រៅរូបកាយទេ តែអ្នកណាដែលសហាយស្មន់គ្នា នោះឈ្មោះថាធ្វើបាបដល់រូបកាយខ្លួនឯងផង"។ (១កូរិនថូស ៦:១៨)

Copyright © Gratia Dei Sola Media

# មេរៀនទី ២៤
# ការពោរពេញដោយសេចក្ដីអធិស្ឋាន

**២៤.១.តើការពោរពេញដោយក្ដីអធិស្ឋាន ជាគុណធម៌របស់គ្រីស្ទបរិស័ទមែនទេ?**

មែនហើយ ត្បិតការពោរពេញដោយសេចក្ដីអធិស្ឋាន គឺជាភ័ស្ដុតាងនៃការសន្ទនាពិត អ្នកនិពន្ធទំនុកដម្កើងបានពោលថា៖ "ព្រះយេហូវ៉ា ទ្រង់គង់នៅជិតនឹងអស់អ្នកដែលអំពាវនាវដល់ទ្រង់ គឺអស់អ្នកដែលអំពាវនាវដល់ទ្រង់ដោយពិតត្រង់"។ (ទំនុកដម្កើង១៤៥:១៨)

**២៤.២.អ្នកមិនជឿជាច្រើនទៀតក៏អធិស្ឋានយ៉ាងងប់ងល់មែនទេ?**

មែនហើយ ប៉ុន្តែពួកគេកំពុងអធិស្ឋានទៅកាន់រូបបដិមា ឬព្រះដែលមនុស្សតែងស្រមើស្រមៃប៉ុណ្ណោះ ហោរាអេសាយប្រាប់យើងរាល់គ្នាថា មនុស្សដែលមិនបានកើតជាថ្មីនឹងមិនស្រែករកព្រះជាម្ចាស់ដ៏មានព្រះជន្មរស់នៅ និងជាព្រះដ៏ពិតនោះឡើយ។ លោកបាននិយាយថា "ត្បិតយើងខ្ញុំទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្សដែលមិនស្អាត ហើយអស់ទាំងអំពើសុចរិតរបស់យើងខ្ញុំក៏ដូចជាអាវកខ្វក់ ហើយយើងខ្ញុំរាល់គ្នាស្វិតក្រៀមទៅដូចជាស្លឹកឈើ ហើយអំពើទុច្ចរិតរបស់យើងខ្ញុំក៏ផាត់យកយើងខ្ញុំទៅដូចជាខ្យល់ ឥតមានអ្នកណាមួយ ដែលអំពាវនាវដល់ព្រះនាមទ្រង់ ឬដែលដាស់តឿនខ្លួនឯងឱ្យតោងទ្រង់ឡើយ"។ (អេសាយ ៦៤:៦-៧)


Copyright © Gratia Dei Sola Media

## ២៩.៣.តើអ្នកអាចបណ្តុះការពោរពេញដោយ សេចក្តីអធិស្ឋាន យ៉ាងដូចម្តេច?

វិធីមួយដ៏សំខាន់គឺ ក្រោកពីព្រលឹមរាល់ថ្ងៃ រួចអធិស្ឋានដូចព្រះអម្ចាស់យេស៊ូវ "កាលនៅងងឹត មិនទាន់ភ្លឺស្រាងនៅឡើយនោះទ្រង់តើនឡើង បានយាងចេញទៅឯទីស្ងាត់រួចអធិស្ឋាននៅទីនោះ"។ (ម៉ាកុស ១:៣៥)

## ២៩.៤.តើអ្នកត្រូវអធិស្ឋានតែនៅពេលព្រឹកទេមែនទេ?

ទេ! មិនមែនទេ អ្នកត្រូវ "អធិស្ឋានឥតឈប់ឈរ"។ (១ថែស្សាឡូនីច ៥:១៧)

## ២៩.៥.អធិស្ឋានឥតឈប់ឈរ តើមានន័យយ៉ាងដូចម្តេច?

គឺមានន័យថា អធិស្ឋាននៅរាល់ពេលណាដែលមានឱកាសសម្រាប់អធិស្ឋាន។ ការនេះក៏ទាមទារឱ្យមាននូវជីវិតដែលមានវិន័យក្នុងការអធិស្ឋាន ដូចជាហោរាដានីយ៉ែល ត្បិត "លោកលុតជង្គង់ចុះអធិស្ឋាន ហើយអរព្រះគុណដល់ព្រះរបស់លោក១ថ្ងៃ៣ដង ដូចជាកាលពីមុន"។ (ដានីយ៉ែល ៦:១០)

## ២៩.៦.តើអ្នកត្រូវអធិស្ឋានដោយបិទភ្នែករបស់អ្នកទាំងឱនមុខចុះរហូតមែនទេ?

ទេ! មិនមែនទេ លោកនេហេមាបានធ្វើជាឧទាហរណ៍ដ៏ល្អសម្រាប់យើងរាល់គ្នាស្រាប់ ដោយអធិស្ឋានមុនពេលលោកផ្តល់ចម្លើយតបនឹងសំនួររបស់ស្តេច "ស្តេចទ្រង់មានបន្ទូល

Copyright © Gratia Dei Sola Media

សួរខ្ញុំថា ដូច្នេះតើអ្នកចង់បានអ្វី ខ្ញុំក៏អធិស្ឋានដល់ព្រះនៃស្ថានសួគ៌ រួចខ្ញុំទូលដល់ស្តេចថា...”។ (នេហេមា ២:៤-៥)

**២៤.៧.ចុះបើអ្នកមិនដឹងអធិស្ឋានយ៉ាងម៉េច ឬមិនដឹងអធិស្ឋានពីអ្វីផងនោះ?**

ព្រះវិញ្ញាណបរិសុទ្ធនឹងជួយអ្នក ត្បិតសាវ័កប៉ុលបានមានប្រសាសន៍យ៉ាងច្បាស់ថា៖ “ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្តីកំសោយរបស់យើងបែបដូច្នោះដែរ ត្បិតយើងមិនដឹងជាគួរអធិស្ឋានសូមអ្វីទេ តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើងដោយដំងូរដែលរកថ្លែងពុំបានវិញ ប៉ុន្តែព្រះអង្គដែលស្ទង់ចិត្តទ្រង់ជ្រាបនូវគំនិតនៃព្រះវិញ្ញាណ ត្បិតព្រះវិញ្ញាណទ្រង់អង្វរជួសពួកបរិសុទ្ធ ឱ្យត្រូវនឹងព្រះទ័យព្រះ”។
(រ៉ូម ៨:២៦-២៧)

 Copyright © Gratia Dei Sola Media

# មេរៀនទី ២៥
# ការស្គាល់ខុសត្រូវ

## ២៥.១.តើវាសំខាន់មែនទេ ដែលត្រូវស្គាល់ខុសត្រូវ?

វាពិតជាសំខាន់ ត្បិតលោកសាវ័កយ៉ូហានមានប្រសាសន៍ថា "ពួកស្ងួនភ្ងាអើយ កុំឱ្យជឿគ្រប់ទាំងវិញ្ញាណឡើយ ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឱ្យបានដឹងជាមកពីព្រះឬមិនមែន ត្បិតមានហោរាក្លែងក្លាយជាច្រើននាក់ កើតក្នុងលោកិយនេះ"។ (១យ៉ូហាន ៤:១)

## ២៥.២.តើព្រះយេស៊ូវមិនបានមានបន្ទូលថា "កុំឱ្យថ្កោលទោសគេឡើយ ដើម្បីមិនឱ្យមានគេថ្កោលទោសអ្នកវិញ" ទេឬ?

ទ្រង់បានមានបន្ទូលដូច្នេះមែន ប៉ុន្តែទ្រង់ក៏មានបន្ទូលដែរថា "កុំឱ្យជំនុំជម្រះតាមភាព ដែលមើលតែខាងក្រៅឡើយ ត្រូវជំនុំជម្រះតាមសេចក្តីសុចរិតវិញ"។ (យ៉ូហាន ៧:២៤)

## ២៥.៣.តើមានរឿងអ្វីកើតឡើងបើសិនជាយើងមិនស្គាល់ខុសត្រូវ?

យើងអាចនឹងត្រូវគេនាំទៅរកផ្លូវខុសយ៉ាងងាយ ដូចជា"កូនតូចទាំងត្រូវគ្រប់អស់ ទាំងខ្យល់នៃសេចក្តីបង្រៀនឆបោក ហើយបក់ផាត់យើងចុះឡើង ដោយសេចក្តីឆបោករបស់ផងមនុស្សហើយដោយឧបាយកល ដែលគេប្រើនឹងនាំឱ្យវង្វេងទៀតឡើយ"។ (អេភេសូរ ៤:១៤)

## ២៥.៤.តើអ្នកត្រូវអនុវត្តការស្គាល់ខុសត្រូវយ៉ាងដូចម្តេច?

"ចូរលមើលគ្រប់ទាំងអស់ ហើយកាន់ខ្ជាប់តាមសេចក្តីដែលត្រឹមត្រូវ"។ (១ថែស្សាឡូនិច ៥:២១)

## ២៥.៥.តើអ្នកអាចលមើលគ្រប់ការទាំងអស់យ៉ាងដូចម្តេច?

ដោយប្រៀបធៀបនឹងបទគម្ពីរ ត្បិតលោកហោរាអេសាយមានប្រសាសន៍ថា "ចូរទៅបើកគម្ពីរបញ្ញាត្តិ និងសេចក្តីបន្ទាល់មើល បើគេនិយាយមិនត្រូវនឹងព្រះបន្ទូលនោះ នោះគ្មានពន្លឺរះនៅក្នុងខ្លួនទេ"។ (អេសាយ ៨:២០)

## ២៥.៦.តើអ្នកអាចប្រើបទគម្ពីរដើម្បីនឹងលមើលគ្រប់ការទាំងអស់យ៉ាងដូចម្តេច?

ដោយរក្សាទុកបទគម្ពីរ និងគោលជំនឿលើបទគម្ពីរនៅក្នុងចិត្តរបស់អ្នក។ អ្នកសរសេរទំនុកដម្កើងពោលថា "ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឱ្យទូលបង្គំធ្វើបាបទាស់នឹងទ្រង់ឡើយ"។
(ទំនុកដម្កើង ១១៩:១១)

## ២៥.៧.តើអ្នកអាចបណ្តុះការស្គាល់ខុសត្រូវតាមវិធីណាទៀត?

គ្រូគង្វាល និងគ្រូបង្រៀន គឺសុទ្ធតែជាមនុស្សដែលព្រះជាម្ចាស់ប្រទានមក ដើម្បីជួយយើងឱ្យលូតលាស់ក្នុងភាពពេញវ័យ និងការស្គាល់ខុសត្រូវខាងឯវិញ្ញាណ។ អ្នកនឹងរៀនពីពួកគាត់ អ្នកក៏នឹងប្រៀបធៀបអ្វី ដែលពួកគាត់និយាយទៅនឹងបទគម្ពីរ។ អ្នកនឹងធ្វើឱ្យដូចជាពួកអ្នកក្រុង


Copyright © Gratia Dei Sola Media

បេរា ត្បិតមាននិយាយពីពួកគេថា "រីឯពួកអ្នកស្រុកនោះ មានចិត្តល្អជាងពួកអ្នកនៅស្រុកថែស្សាឡូនិច ពួកគេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃ ឱ្យបានដឹងជាសេចក្តីទាំងនោះត្រូវឬមិនត្រូវ"។ (កិច្ចការ ១៧:១១)

## ២៥.៨.តើមានគ្រូគង្វាលណា ឬគ្រូបង្រៀនណាដែលអ្នកត្រូវជៀងវាងទេ?

ពិតជាមានក្នុងចំណោមពួកគេជាច្រើននាក់ គឺជាចចកពាក់ស្បែកចៀម ត្បិតលោកសាវ័កប៉ុលបានមានប្រសាសន៍ថា "ឱបងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នាឱ្យចំណាំមើល អស់អ្នកបណ្តាលឱ្យបែកបាក់គ្នា ហើយនាំឱ្យមានសេចក្តីរវាតចិត្តខុសនឹងសេចក្តីដែលអ្នករាល់គ្នាបានរៀនមក ត្រូវឱ្យបែរចេញពីអ្នកទាំងនោះ ត្បិតមនុស្សបែបយ៉ាងនោះមិនមែនគោរពប្រតិបត្តិ ដល់ព្រះគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នាទេ! គេបម្រើតែពោះគេវិញ ទាំងបញ្ឆោតចិត្តមនុស្សស្លូតត្រង់ដោយពាក្យផ្អែមពិរោះ និងពាក្យបញ្ចើចផង"។ (រ៉ូម ១៦:១៧-១៨)

Copyright © Gratia Dei Sola Media